# ក្របខណ្ឌគរុកោសល្យសតវត្សរ៍ទី២១សម្រាប់ប្រទេសកម្ពុជា

## ក្រសួងអប់រំ យុវជន និងកីឡា

ខែវិច្ឆិកា ឆ្នាំ២០២០
រាជធានីភ្នំពេញ ប្រទេសកម្ពុជា

# មាតិកា

*បញ្ជីអក្សរកាត់*

១. **គោលបំណង និងរបៀបប្រើប្រាស់ឯកសារ**........................................ ១

១.១ កាលានុវត្តសម្រាប់ការរៀបចំក្របខណ្ឌគរុកោសល្យថ្មី

១.២ រចនាសម្ព័ន្ធនៃការរៀបចំសៀវភៅ

២. **មូលហេតុដែលប្រទេសកម្ពុជាត្រូវការក្របខណ្ឌគរុកោសល្យថ្មី**................ ៤

២.១ ការវិវត្តគរុកោសល្យនៅប្រទេសកម្ពុជា និងបញ្ហាពាក់ព័ន្ធសំខាន់ៗ

២.២ តម្រូវការសិក្សាសម្រាប់សតវត្សរ៍ថ្មី

៣. **លក្ខណៈខុសគ្នារវាង គោលវិធី វិធីសាស្ត្រ និងល្បិច បង្រៀន** ១១

៤. **ការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីគរុកោសល្យដើម្បីពង្រឹងប្រសិទ្ធភាពវិធីសាស្ត្របង្រៀនថ្មី**.................................................... ១៦

៤.១ និយមន័យប្រព័ន្ធអេកូឡូស៊ីការសិក្សា

៤.២ ប្រព័ន្ធអេកូឡូស៊ីគរុកោសល្យនៅក្នុងសាលាជំនាន់ថ្មីដែលសាលារៀនសាធារណៈអាចសិក្សាជាបទពិសោធន៍

៥. **វិធីសាស្ត្របង្រៀនបែបសំយោគ** ( Hybridized Teaching )**សម្រាប់ការសិក្សាបែបបញ្ញត្តិ**................................ ២២

៥.១ គុណសម្បត្តិនៃការអភិវឌ្ឍវិធីសាស្ត្របង្រៀនបែបសំយោគ

៥.២ និយមន័យ ការសិក្សាបែបស្ថាបនានិយម

៥.៣ របៀបដែលការសិក្សាបែបស្ថាបនានិយមអាចលើកកម្ពស់ការសិក្សាបែបបញ្ញត្តិ

៥.៤ ការសិក្សាបែបស្ថាបនានិយម និងបច្ចេកវិទ្យា

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធ ១៖ ទស្សនវិជ្ជាអប់រំទាំង ៧ ២៨

ឧបសម្ព័ន្ធ ២៖ អន្តរកាលក្នុងការអប់រំ - ការផ្លាស់ប្តូរពីសតវត្សរ៍ទី២០ ទៅ ទី២១ ៣២

ឧបសម្ព័ន្ធ ៣៖ យុទ្ធសាស្ត្រគរុកោសល្យក្នុងសាលារៀនជំនាន់ថ្មី ៣៦

ឧបសម្ព័ន្ធ ៤៖ ការយល់ដឹងអំពីការកែទម្រង់ដំណើរការបង្រៀន និងរៀនក្នុងប្រទេសកម្ពុជា ៤១

# បញ្ជីអក្សរកាត់

| | |
|---|---|
| CBL | ការសិក្សាបែបបញ្ញត្តិ |
| CFS | សាលាកុមារមេត្រី |
| CL | ការសិក្សាបែបសហការ |
| CMOE | មជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រងនិងប្រសិទ្ធភាពអង្គការ |
| IBL | ការសិក្សាបែបរិះរក |
| ICT | បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| NGS | សាលារៀនជំនាន់ថ្មី |
| PBL | ការសិក្សាអាស្រ័យលើបញ្ហា |
| PLC | សហគមន៍សិក្សាវិជ្ជាជីវៈគ្រូ |
| TTI | វិទ្យាស្ថានបណ្តុះបណ្តាលគ្រូ |

# ១. គោលបំណង និងរបៀបប្រើប្រាស់សៀវភៅ

## ១.១ កាលានុវត្តសម្រាប់ការរៀបចំក្របខណ្ឌគរុកោសល្យថ្មី

នៅពេលប្រទេសកម្ពុជា បានឈានចូលក្នុងសតវត្សរ៍ទី២១ យើងសង្កេតឃើញថាមានការបញ្ចូលគោលវិធី និងវិធីសាស្ត្រគរុកោសល្យប្លែកៗជាច្រើន ដើម្បីជួយគ្រូបង្រៀនលើកកម្ពស់ការរៀនសូត្ររបស់សិស្ស។ យ៉ាងណាក៏ដោយ វិធីសាស្ត្របង្រៀនប្លែកៗគ្នាទាំងនេះ តែងតែប្រកួតប្រជែងជាមួយគ្នា បើទោះបីជាពួកវាមានល្បិចបង្រៀនដូចគ្នាក្នុងករណីជាច្រើនក៏ដោយ។ ការជំរុញឱ្យគ្រូបង្រៀន ថាត្រូវប្រើប្រាស់វិធីសាស្ត្រមួយនេះ ជាជាងវិធីសាស្ត្រមួយផ្សេងទៀត គឺជាជំហរមិនត្រឹមត្រូវ ពីព្រោះវាបានធ្វើឱ្យគ្រូបង្រៀនកាន់តែមានការភ័ន្តច្រឡំ។ គោលបំណងរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការអភិវឌ្ឍឯកសារនេះ គឺដើម្បីផ្តល់ជាក្របខណ្ឌគរុកោសល្យដែលអាចបត់បែនបាន សម្រាប់គ្រូបង្រៀនដើម្បីពិចារណា ដោះស្រាយបញ្ហាភ័ន្តច្រឡំមួយចំនួនខាងលើ និងផ្តល់ជាការណែនាំក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀនផ្សេងៗទៀតនៅក្នុងបរិបទផ្សេងគ្នា ( ទៅតាមបរិបទតម្រូវ) ដោយមិនចាំបាច់ធ្វើការបង្រៀនតឹងរ៉ឹងនិងបែបរូបមន្តខ្លាំងពេកនោះទេ។ ជារួម ឯកសារនេះមានបំណងផ្តល់នូវ " សេរីភាពនៅក្នុងរចនាសម្ព័ន្ធ" ដើម្បីណែនាំគ្រូបង្រៀនឱ្យចេះធ្វើផែនការ និងអនុវត្តមេរៀនរបស់ពួកគេប្រកបដោយប្រសិទ្ធភាព។

> *... ឯកសារនេះមានបំណងផ្តល់នូវ "សេរីភាពនៅក្នុងរចនាសម្ព័ន្ធ" ដើម្បីណែនាំគ្រូបង្រៀនឱ្យចេះធ្វើផែនការ និងអនុវត្តមេរៀនរបស់ពួកគេប្រកបដោយប្រសិទ្ធភាព។*

ជាទូទៅនៅក្នុងប្រព័ន្ធអប់រំ អ្នកបង្កើតគោលនយោបាយចង់ផ្តល់ឱ្យគ្រូបង្រៀននូវសេរីភាពក្នុងការជ្រើសរើសវិធីបង្រៀនតាមដែលអាចធ្វើទៅបាន ប៉ុន្តែក៏មិនចង់បង្កើតនូវភាពវឹកវរនៅក្នុងប្រព័ន្ធអប់រំផងដែរ។ ម្យ៉ាងវិញទៀត រចនាសម្ព័ន្ធច្រើនពេក អាចបង្កើតបរិយាកាសរៀនសូត្រដែលមានលក្ខណៈមេកានិច និងភាពអន់ថយ ហើយឈានទៅរកស្ថានភាពមួយដែលគ្រូបង្រៀនមិនយល់ពី "មូលហេតុ" ដែលពួកគេកំពុងប្រើវិធីសាស្ត្រជាក់លាក់ណាមួយដែលប្រព័ន្ធអប់រំបានជំរុញ។ ដូច្នេះក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា ឯកសារនេះ នឹងផ្តល់នូវក្របខណ្ឌគរុកោសល្យដែលមានលក្ខណៈជាផ្លូវកណ្តាល ដើម្បីឆ្លើយតបនឹងបញ្ហាខាងលើ។

ថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡាបានព្យាយាមផ្តល់អាទិភាពដល់ការធ្វើសមាហរណកម្មការសិក្សាបែបបញ្ញត្តិ (CBL) ទៅក្នុងការរៀបចំឡើងវិញនូវកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ដែលបានផ្សព្វផ្សាយនៅវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ (TTIs) ។ ទោះបីការប្រើប្រាស់សៀវភៅសិក្សាគោលនៅតែជាមុខងារដ៏សំខាន់នៃប្រព័ន្ធអប់រំនៅកម្ពុជាក៏ដោយ ក៏ក្រសួងអប់រំ យុវជន និងកីឡាចង់ឱ្យគ្រូបង្រៀនបំពេញបន្ថែមការសិក្សាក្នុងសៀវភៅសិក្សាគោល ដោយធានាថាចំណេះដឹងខ្លឹមសារត្រូវបាន

អនុវត្តក្នុងបរិបទពិតពិត ដើម្បីឱ្យវាកាន់តែមានអត្ថន័យនិង ពាក់ព័ន្ធជីវភាពរស់នៅជាក់ស្តែង។ នៅពេលដែលក្រសួង អប់រំ យុវជន និងកីឡាពិចារណាលើការអភិវឌ្ឍសេចក្តី ណែនាំថ្មី សម្រាប់គ្រូបង្រៀនអំពីវិធីសាស្ត្របង្រៀន យើងត្រូវ យល់ច្បាស់នូវការបង្កើតរចនាសម្ពន្ធ័ ដែលមានភាពបត់បែន ជៀសវាងការណែនាំបែបរូបមន្ត និងលើកកម្ពស់សមត្ថភាព គ្រូបង្រៀន ឱ្យចេះផ្សំវិធីសាស្ត្រផ្សេងគ្នា ដែលឆ្លើយតបយ៉ាង ល្អបំផុត ទៅនឹងបរិបទដែលពួកគេកំពុងបង្រៀនជាក់ស្តែង។



***តើការសិក្សាបែបបញ្ញត្តិមានន័យដូចម្តេច?***

*ការសិក្សាបែបបញ្ញត្តិ ជំរុញដោយ "គំនិតធំ" ជាជាងខ្លឹមសារជាក់លាក់។ ការសិក្សាបែបបញ្ញត្តិ បង្កើតនូវអត្ថន័យ "ពិតពិត" ចំពោះចំណេះដឹងខ្លឹមសារ និងបំណិន តាមរយៈការដឹកនាំសិស្សឱ្យពិចារណាលើបរិបទដែលពួកគេកំពុងរស់នៅជាក់ស្តែង។*

## ១.២ រចនាសម្ព័ន្ធសៀវភៅ

សៀវភៅនេះ បង្កើតឡើងដោយឈរលើសារៈសំខាន់ នៃគោលការណ៍ការសិក្សាបែបស្ថាបនានិយម។ ការសិក្សា បែបស្ថាបនានិយមគឺជាមូលដ្ឋានគ្រឹះសម្រាប់ក្របខណ្ឌ គរុកោសល្យថ្មី ពីព្រោះវាគាំទ្រដល់ស្ថាបត្យកម្មបញ្ញត្តិទូលំទូលាយនៃវិធីសាស្ត្របង្រៀនជាច្រើនដែល កំពុងប្រើជាទូទៅនៅក្នុងប្រទេសកម្ពុជា (ឧ. ការសិក្សាបែបរិះរក ការសិក្សាផ្អែកលើបញ្ហា ការសិក្សា បែបសហការ ជាដើម) ។ ប៉ុន្តែមុននឹងស្វែងយល់ទៅលើការសិក្សា បែបស្ថាបនានិយម អ្នកអប់រំត្រូវយល់ដឹងជាមុនសិន ពីដំណើរវិវត្តនៃ ការផ្លាស់ប្តូរគរុកោសល្យនៅកម្ពុជា និងរបៀបដែលការផ្លាស់ប្តូរទាំង នេះកើតឡើងក្រោមឥទ្ធិពលនៃការផ្លាស់ប្តូរសេដ្ឋកិច្ចនៅក្នុងសត វត្សរ៍ទី ២១។ ការយល់ដឹងបានល្អប្រសើរពីប្រភពនៃការអនុវត្ត គរុកោសល្យនឹងជួយអ្នកអានឱ្យយល់កាន់តែច្បាស់ពីទិសដៅ និង មូលហេតុនៃការបង្កើតក្របខណ្ឌគរុកោសល្យថ្មីនេះ។

*ការយល់ដឹងបានល្អប្រសើរពីប្រភពនៃការអនុវត្តគរុកោសល្យនឹងជួយអ្នកអានឱ្យយល់កាន់តែច្បាស់ពីទិសដៅ និងមូលហេតុនៃការបង្កើតក្របខណ្ឌគរុកោសល្យថ្មីនេះ។*

នៅក្នុងផ្នែកបន្ទាប់នៃឯកសារនេះ ព្យាយាមពន្យល់ពាក្យបច្ចេកទេសមួយចំនួនដែលបានប្រើជា ញឹកញាប់ ដែលពេលខ្លះពាក្យទាំងនេះអាចប្រើប្រាស់ជំនួសគ្នាបាន ទន្ទឹមនឹងនោះ ពួកវាក៏មាន ឋានានុក្រមជាប្រព័ន្ធគរុកោសល្យក្នុងការអប់រំផងដែរ។ ឧទាហរណ៍ អ្នកអប់រំខ្លះយល់ច្រឡំថា ការ សិក្សាបែបស្ថាបនានិយម គឺជាវិធីសាស្ត្រមួយ ដែលប្រកួតប្រជែងគ្នានឹងវិធីសាស្ត្រផ្សេងៗទៀត ដូចជា ការសិក្សាបែបរិះរក (IBL) ការសិក្សាផ្អែកលើបញ្ហា (PBL) និងវិធីសាស្ត្រដទៃទៀត តែតាមពិតយើង គួរចាត់ទុកថា ការសិក្សាបែបស្ថាបនានិយម វាមានលក្ខណៈជាប្រព័ន្ធទស្សនវិជ្ជាទូលំទូលាយ ឬជា គោលវិធី ដែលរួមបញ្ចូលវិធីសាស្ត្រផ្សេងៗដូចជា IBL និង PBL ។ ជាការពិតណាស់ វិធីសាស្ត្រទាំងនេះ លើកកម្ពស់ល្បិចបង្រៀនដែលមានភាពស្រដៀងគ្នាទៅវិញទៅមក (ឧ. ការងារក្រុមដែលសហការគ្នា

ការស្រាវជ្រាវដោយសិស្ស ការបង្កើតគម្រោងសិក្សា ជាដើម) ។ ដូច្នេះ ផ្នែកនេះជួយអ្នកអានឱ្យយល់កាន់តែច្បាស់ពីអត្ថន័យនៃពាក្យទាំងនេះ ដូចជា គោលវិធី វិធីសាស្ត្រ និងល្បិច ព្រមទាំងពន្យល់ពីរបៀបដែលពាក្យទាំងនេះទាក់ទងគ្នាទៅវិញទៅមកតាមឋានានុក្រម។ ការយល់ដឹងទូទៅទាំងនេះ នឹងជួយការពារការយល់ច្រឡំ និងជួយសម្រួលដល់ការយល់ដឹងកាន់តែច្បាស់អំពីរបៀបដែលការសិក្សាបែបស្ថាបនានិយម មានទំនាក់ទំនងទៅនឹងវិធីសាស្ត្រផ្សេងៗទៀតដែលបានប្រើប្រាស់ជាទូទៅនៅប្រទេសកម្ពុជា។

***ឋានានុក្រមនៃប្រព័ន្ធគរុកោសល្យ***

*គោលវិធី*

↓

*វិធីសាស្ត្រ*

↓

*ល្បិច*

នៅចុងបញ្ចប់ឯកសារនេះ សង្កត់ធ្ងន់លើសារៈសំខាន់នៃការបង្កើតបរិយាកាសគាំទ្រមួយក្នុងសាលារៀន ដែលអាចបង្កើនប្រសិទ្ធភាពនៃវិធីសាស្ត្របង្រៀនផ្សេងៗ ដែលបានលើកកម្ពស់ដោយ ក្រសួង។ ពោលគឺគ្មានវិធីសាស្ត្របង្រៀនណាអាចមានប្រសិទ្ធភាពពេញលេញបានទេ បើសិនគ្មានការគាំទ្រដល់រចនាសម្ព័ន្ធស្ថាប័ន និងធនធានដែលគួរតែមាននៅក្នុងកម្រិតណាមួយនៅក្នុងសាលារៀន។ កត្តាគាំទ្រទាំងនេះនៅក្នុងសាលារៀនមួយ ហៅថាប្រព័ន្ធបរិស្ថានគរុកោសល្យ (Pedagogical Eco-system)។ សេចក្តីពន្យល់នៅក្នុងផ្នែកនេះផ្អែកលើបទពិសោធន៍នៃកំណែទម្រង់សាលារៀនជំនាន់ថ្មី ដែលបានបង្ហាញថា ការប្រែប្រួលការអនុវត្តផ្នែកគរុកោសល្យដោយប្រសិទ្ធិភាពទៅបាន គឺដោយសារកត្តាគាំទ្រផ្សេងទៀតនៅក្នុងបរិស្ថាន និងវប្បធម៌របស់សាលារៀន ដូចជាបណ្ណាល័យទំនើប បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ គ្រឿងបរិក្ខារព័ត៌មានវិទ្យា សហគមន៍សិក្សាវិជ្ជាជីវៈគ្រូ (PLC) ប្រព័ន្ធផ្តល់ប្រឹក្សាគរុកោសល្យ និងរចនាសម្ព័ន្ធស្ថាប័នដទៃទៀត។ ដូច្នេះ គេមិនគួរគិតថាវិធីសាស្ត្របង្រៀនអាចដំណើរការទៅបានតែឯកឯងនោះទេ ប៉ុន្តែផ្ទុយទៅវិញ ត្រូវភ្ជាប់ជាមួយលក្ខណៈពិសេសផ្សេងទៀតនៃ បរិស្ថានអប់រំ។

គួរកត់សម្គាល់ថា សៀវភៅនេះមានបំណងពន្យល់អំពីក្របខណ្ឌគរុកោសល្យថ្មីរបស់ ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំង ប្រើប្រាស់ជាសៀវភៅសម្រាប់បង្រៀនផងដែរ។ អាស្រ័យហេតុនេះ ផ្នែកនីមួយៗក្នុងសៀវភៅនេះ ផ្តល់នូវឯកសារយោងជាភាសាអង់គ្លេស និងខ្មែរសម្រាប់ការអានបន្ថែម (ឬប្រើក្នុងវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ សម្រាប់គរុនិស្សិតអានបន្ថែម) ព្រមទាំងមានសំណួរពិភាក្សាដែលជួយដល់ការសម្របសម្រួលក្នុងសិក្ខាសាលា និងជំរុញអន្តរកម្មថ្នាក់រៀននៅតាមវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ។ នៅក្នុងសំណួរពិភាក្សានេះ មិនចាំបាច់ស្វែងរកចម្លើយត្រឹមត្រូវ ឬខុសនោះទេ។ ផ្ទុយទៅវិញ គោលដៅគឺចង់ឱ្យអ្នកអប់រំចែះពិភាក្សាបញ្ហាជាមួយគ្នា ដើម្បីទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅអំពីបញ្ហាដែលបានលើកឡើងនៅក្នុងផ្នែកនីមួយៗ។

ជាចុងក្រោយ នៅក្នុងឧបសម្ព័ន្ធសៀវភៅនេះ មានបញ្ចូលនូវឯកសារយោងបន្ថែមមួយចំនួន និងបទបង្ហាញជាស្លាយស្រាប់ (សូមមើលឧបសម្ព័ន្ធទី២, ៣, និង ៤) ពាក់ព័ន្ធប្រធានបទដែលបានពិពណ៌នាខាងលើ ដែលអាចមានប្រយោជន៍សម្រាប់អ្នកសម្របសម្រួលធ្វើបទបង្ហាញក្នុងវគ្គសិក្ខាសាលាវិក្រឹតការ និងការបណ្តុះបណ្តាលដំបូង។

# ២. មូលហេតុដែលប្រទេសកម្ពុជាត្រូវការក្របខណ្ឌគរុកោសល្យថ្មី

## ២.១ ការវិវត្តគរុកោសល្យនៅប្រទេសកម្ពុជា និងបញ្ហាពាក់ព័ន្ធសំខាន់ៗ

គុណសម្បត្តិក្របខណ្ឌគរុកោសល្យថ្មី ដែលបង្ហាញក្នុងឯកសារនេះកាន់តែមានភាពច្បាស់លាស់ នៅពេលពិនិត្យពីការវិវត្តប្រវត្តិសាស្រ្តគរុកោសល្យនៅកម្ពុជាក្នុងរយៈពេល ២៥ឆ្នាំចុងក្រោយនេះ។ ការវិវត្តនេះបានឆ្លុះឱ្យឃើញពីការស្វែងរកស្តង់ដាត្រឹមត្រូវឥតខ្ចោះ ( Orthodoxy ) និងរូបមន្តគរុកោសល្យបែបសាមញ្ញៗ។ ដំណើរស្វែងរករូបមន្តសាមញ្ញនេះ ពេលខ្លះវាសាមញ្ញហួសហេតុពេកដោយគ្រាន់តែនិយាយថា 'រៀនដោយធ្វើ' និង 'សិស្សធ្វើច្រើន គ្រូធ្វើតិច'។ ការលើកឡើងបែបនេះ គឺមិនខុសទេ ប៉ុន្តែការឱ្យនិយមន័យរបៀបបង្រៀនរបស់គ្រូបង្រៀនងាយៗបែបនេះ ធ្វើឱ្យបិទបាំងអំពីតម្រូវការនិងការឆ្លើយតបចំពោះបរិបទស្មុគស្មាញនៅក្នុងថ្នាក់រៀន។ ការបង្រៀនមិនគួរប្រើវិធីសាស្រ្តតែមួយលប់លើវិធីសាស្រ្តផ្សេងៗទៀតនោះទេ។ ដំណើរស្វែងរកមគ្គុទ្ទេសក៏របៀបបង្រៀនសាមញ្ញជ្រុលពេកបែបនេះ នាំឱ្យមានផលវិបាកមិនល្អមួយចំនួនដូចខាងក្រោម៖

- ការអនុវត្តការអប់រំមានលក្ខណៈបែបរូបមន្ត និងរ៉ាយរ៉ាប់កម្រិតខ្ពស់។
- គ្រូបង្រៀនគ្រាន់តែគិតអំពីបច្ចេកទេស/ល្បិច 'អ្វី' ដែលពួកគេត្រូវប្រើក្នុងការបង្រៀន ជាជាងស្វែងយល់អំពី 'ហេតុអ្វី' ដែលពួកគេកំពុងប្រើបច្ចេកទេស/ល្បិចនោះ។

ផលវិបាកចុងក្រោយនេះ បង្កើតបញ្ហាជាច្រើន ព្រោះថា នៅពេលដែលគ្រូបង្រៀនមិនដឹងពី 'ហេតុអ្វី' ពួកគេកំពុងប្រើវិធីសាស្រ្តបង្រៀនណាមួយ នាំឱ្យការបង្រៀនរបស់ពួកគេក្លាយជាបែបមេកានិច ដោយភាគច្រើនគ្រាន់តែធ្វើតាមសៀវភៅសិក្សាគោល។ ដូចបានកត់សម្គាល់ពីមុន ក្រសួងអប់រំ យុវជន និងកីឡា ចង់លើកកម្ពស់ការសិក្សាបែបបញ្ញត្ត ផ្ទុយនឹងការរៀនសូត្រណាមួយ ដែលជំរុញដោយសៀវភៅសិក្សាគោលតែមួយមុខ។

> **ប្រអប់ទី១៖ ការបង្រៀនបែបរ៉ាយរ៉ាប់ & ឆ្លុះបញ្ចាំង**
>
> • **ការបង្រៀនបែបរ៉ាយរ៉ាប់**លើកកម្ពស់វិធីរៀនតាមជំហានដែលបានរៀបចំរួចស្រេចសម្រាប់គ្រូអនុវត្តតាម ហើយគ្រូបង្រៀនមានគម្លាតបត់បែនតិចតួច។ ឧទាហរណ៍ទូទៅអំពីការបង្រៀនបែបរ៉ាយរ៉ាប់ រួមមាន កិច្ចតែងការស្តង់ដាជំហានបង្រៀនថេរ និងការរៀនតាមសៀវភៅសិក្សាគោល។
>
> · **ការបង្រៀនបែបឆ្លុះបញ្ចាំង**លើកកម្ពស់វិធីបង្រៀន ដែលគ្រូមានសេរីភាពច្រើនក្នុងការបញ្ចូលគ្នានូវបច្ចេកទេស/ល្បិចពីវិធីសាស្រ្តជាច្រើន ដើម្បីសម្របទៅនឹងបរិបទថ្នាក់រៀនរបស់គាត់។ តាមរយៈការបង្រៀនបែបឆ្លុះបញ្ចាំង គ្រូបង្រៀនចេះធ្វើស្វ័យវាយតម្លៃលើការបង្រៀនរបស់ខ្លួនដោយពិនិត្យមើលគរុកោសល្យ ស្វែងរកហេតុផល និងចំណុចខ្លាំងលើយុទ្ធសាស្រ្តរបស់ពួកគេ និងកំណត់រកអ្វីដែលត្រូវកែលម្អ។

កំហុសដ៏ធំបំផុតមួយនៅក្នុងការអនុវត្តគរុកោសល្យ គឺភាពតានតឹងរវាងការបង្រៀនបែបរ៉ាយរ៉ាប់ និងឆ្លុះបញ្ចាំង ( សូមមើលប្រអប់ទី ១ )។ គំរូបង្រៀនទាំងពីរនេះមិនមែនជាវិធីសាស្រ្តបង្រៀននោះទេ ប៉ុន្តែជាយុទ្ធសាស្រ្តជា

ប្រព័ន្ធមួយដែលសាលារៀនឬអាជ្ញាធរអប់រំ ប្រើប្រាស់ដើម្បីធានាឱ្យការបង្រៀនមានប្រសិទ្ធភាព។ ឧទាហរណ៍ ការបង្រៀនបែបវ៉ាយវ៉ាប់ មានគោលដៅណែនាំដល់គ្រូបង្រៀនភាគច្រើនដែលមានគុណវុឌ្ឍិកម្រិតទាប ហើយប្រាប់ជំហានបង្រៀនច្បាស់លាស់អំពី 'អ្វី' និង 'របៀប' ដែលពួកគេត្រូវបង្រៀនដោយមានគម្លាតបត់បែនតិចតួច។ ការបង្រៀនបែបវ៉ាយវ៉ាប់មានប្រវត្តិយូរលង់ណាស់មកហើយនៅក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ នៅពេលដែលគុណវុឌ្ឍិគ្រូបង្រៀនភាគច្រើនមានកម្រិតទាប។ បញ្ហាទូទៅដែលកើតចេញពីការបង្រៀនបែបវ៉ាយវ៉ាប់គឺថាវាមិនអើពើនឹងបរិបទស្មុគស្មាញនៃការសិក្សា និងមិនអនុញ្ញាតឱ្យមានការបត់បែនច្រើនដល់គ្រូបង្រៀនក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលជាច្រើនដែលមានពីថ្នាក់រៀនមួយទៅថ្នាក់រៀនមួយទៀត។ ខណៈដែលក្រសួងអប់រំ យុវជន និងកីឡា កំពុងកំណត់អាទិភាពខ្ពស់លើការសិក្សាបែបបញ្ញត្ត និង ការជំរុញឱ្យគ្រូបង្រៀនបង្រៀនសិស្សដោយមិនពឹងផ្អែកទាំងស្រុងលើសៀវភៅសិក្សាគោលតែមួយមុខ វាចាំបាច់ណាស់ដែលគ្រូបង្រៀនត្រូវផ្លាស់ប្តូរយុទ្ធសាស្ត្របង្រៀនបែបវ៉ាយវ៉ាប់។

ម៉្យាងទៀត ការបង្រៀនបែបឆ្លុះបញ្ចាំងលើកទឹកចិត្តគ្រូបង្រៀនឱ្យចេះវាយតម្លៃកម្រិតប្រសិទ្ធភាពការបង្រៀនរបស់ពួកគេកាលពីអតីតកាល និងរបៀបដែលពួកគេអាចផ្លាស់ប្តូរនៅពេលអនាគតដើម្បីធ្វើឱ្យកាន់តែប្រសើរឡើង។ ការអនុវត្តការបង្រៀនដោយឆ្លុះបញ្ចាំងត្រូវប្រើជាមួយវិធីសាស្ត្របង្រៀនណាមួយដែលធ្វើឱ្យកាន់តែមានប្រសិទ្ធភាព។ នេះជាមូលហេតុដែលយើងពណ៌នាការបង្រៀនដោយឆ្លុះបញ្ចាំងថាជា 'ដំណើរការ' សម្រាប់ការបង្រៀន ជាជាងផ្តោតតែលើវិធីសាស្ត្រជាក់លាក់ផ្ទាល់ណាមួយ។ ការបង្រៀនដោយឆ្លុះបញ្ចាំងគឺពាក់ព័ន្ធទៅនឹងក្របខណ្ឌគរុកោសល្យថ្មីដែលបានពិពណ៌នានៅក្នុងឯកសារនេះ ព្រោះវាលើកទឹកចិត្តគ្រូបង្រៀនឱ្យគិតអំពី 'ហេតុអ្វី' ដែលពួកគេគួរប្រើបច្ចេកទេសបង្រៀនជាក់លាក់ណាមួយនៅក្នុងបរិបទជាក់ស្តែងនៃថ្នាក់រៀនរបស់ពួកគេ និងរបៀបដែលពួកគេអាចធ្វើឱ្យបច្ចេកទេសទាំងនេះកាន់តែសមស្របទៅនឹង បរិបទជាក់ស្តែងដែលពួកគេកំពុងជួបប្រទះ។ ការបង្រៀនដោយឆ្លុះបញ្ចាំងក៏មានភាពសមស្របខ្ពស់ទៅនឹងការសិក្សាបែបបញ្ញត្តិ ព្រោះវាជួយជំរុញឱ្យគ្រូបង្រៀនឆ្លុះបញ្ចាំងលើ 'រូបភាពធំ' នៃអ្វីដែលពួកគេចង់ឱ្យសិស្សរបស់ពួកគេរៀនលើសពីអ្វីដែលមាននៅក្នុងសៀវភៅសិក្សាគោល។ ហេតុផលនេះហើយដែល ក្រសួងអប់រំ យុវជន និងកីឡាគាំទ្រឱ្យបញ្ចូលការបង្រៀនដោយឆ្លុះបញ្ចាំងទៅក្នុងក្របខណ្ឌថ្មី ព្រោះវាឆ្លើយតបយ៉ាងខ្លាំងទៅនឹងតម្រូវការជាយុទ្ធសាស្ត្រ នៃការសិក្សាបែបបញ្ញត្តិ។

ជាការពិតណាស់ **ការបង្រៀនបែបវ៉ាយវ៉ាប់** និង**ការបង្រៀនបែបឆ្លុះបញ្ចាំង** តែងតែមាននូវគុណសម្បត្តិ និងគុណវិបត្តិរៀងៗខ្លួន។ ជម្រើសយកវិធីណាមួយអាស្រ័យលើរបៀបដែលប្រព័ន្ធអប់រំ

កំណត់អាទិភាពរបស់វា។ គុណសម្បត្តិ និងគុណវិបត្តិទាំងនេះមានសង្ខេបជូននៅក្នុងតារាង ២.១ ខាងក្រោម.

តារាង ២.១៖ គុណសម្បត្តិ និងគុណវិបត្តិនៃការបង្រៀនបែបរ៉ាយរ៉ាប់ និងបែបផ្ទុះបញ្ចាំង

| | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| **ការបង្រៀនបែបរ៉ាយរ៉ាប់** | • ល្អសម្រាប់បង្រៀនមូលដ្ឋានគ្រឹះ<br>• សមស្របសម្រាប់គ្រូដែលមានកម្រិតបណ្តុះបណ្តាលទាប<br>• គ្រូបង្រៀនមិនចាំបាច់គិតច្រើនពីការបង្រៀនរបស់ពួកគេទេ<br>• ងាយស្រួលសម្រាប់ការងារអធិការកិច្ចតាមដានអនុលោមភាព។ | • មិនមានប្រយោជន៍សម្រាប់ការបង្រៀនបំណិនគិតកម្រិតខ្ពស់ទេ<br>• មិនសមស្របសម្រាប់គ្រូដែលមានសមត្ថភាពខ្ពស់<br>• គ្រូបង្រៀនមានសេរីភាពតិចតួចក្នុងការសម្របការបង្រៀនរបស់ពួកគេទៅនឹងបរិបទជាក់លាក់<br>• គ្រូបង្រៀនមានវិសាលភាពតិចតួចសម្រាប់ការរីកចម្រើនវិជ្ជាជីវៈ |
| **ការបង្រៀនបែបផ្ទុះបញ្ចាំង** | • ល្អសម្រាប់បង្រៀន ទាំងបំណិនគិតកម្រិតទាប និងខ្ពស់<br>• សមស្របសម្រាប់គ្រូដែលមានសមត្ថភាពខ្ពស់<br>• ផ្តល់នូវវិសាលភាពបន្ថែមទៀតសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូ | • គ្រូដែលមានកម្រិតសមត្ថភាពទាបមានការលំបាកច្រើន<br>• មានការលំបាកច្រើនក្នុងការអនុវត្តនិងតាមដាន<br>• ការផ្ទុះបញ្ចាំងត្រូវការពេលវេលាដើម្បីអនុវត្ត |

ទោះបីជាយុទ្ធសាស្ត្របង្រៀនបែបរ៉ាយរ៉ាប់មានភាពសមស្របជួយដល់ការសិក្សារបស់សិស្សកាលពី ២៥ ឆ្នាំមុនក៏ដោយ អ្នកអប់រំជាច្រើននៅក្នុងក្រសួងអប់រំ យុវជន និងកីឡាជឿជាក់ថាឥឡូវនេះដល់ពេលដែលត្រូវឆ្ពោះទៅមុខក្នុងសតវត្សថ្មី ដែលការបង្រៀនបែបផ្ទុះបញ្ចាំងគឺសមស្របជាងសម្រាប់កំណត់ជាអាទិភាពថ្មី។

## ២.២ តម្រូវការការសិក្សាក្នុងសតវត្សថ្មី

ការបង្កើតក្របខណ្ឌគុរុកោសល្យថ្មីនេះក៏ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការផ្លាស់ប្តូរនៅក្នុងសេដ្ឋកិច្ចសតវត្សទី ២១ ផងដែរ។ ជាការពិតណាស់ ចលនាឆ្ពោះទៅរកវិធីសាស្រ្តបង្រៀនថ្មីដូចជា IBL និង PBL ភាគច្រើនត្រូវបានជំរុញដោយល្បឿននៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា និងឥទ្ធិពលរបស់វាទៅលើរបៀបដែលសេដ្ឋកិច្ចដំណើរការ។ ការយល់ដឹងអំពីការផ្លាស់ប្តូរទាំងនេះនឹងជួយឱ្យអ្នកអប់រំយល់អំពីមូលហេតុដែលយើងអនុម័តយកវិធីសាស្រ្តបង្រៀនថ្មី និងការរៀបចំសាលារៀនឡើងវិញតាមគោលដៅក្របខណ្ឌគុរុកោសល្យថ្មីដ៏មានសារៈសំខាន់នេះ។

**ប្រអប់ទី២៖ អ្វីជាការអប់រំបែបសតវត្សទី២១ ?**

ការអប់រំនៅសតវត្សរ៍ទី ២១ គឺជាការអប់រំមួយដែលឆ្លើយតបទៅនឹងការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច បច្ចេកវិទ្យា និងសង្គមដែលកំពុងកើតឡើងក្នុងល្បឿនដែលមិនធ្លាប់មានពីមុន។ វាជាការអប់រំដែលជួយកុមារឱ្យទទួលបានជោគជ័យនៅក្នុងពិភពលោកដែលការងារជាងពាក់កណ្តាលដែលពួកគេនឹងធ្វើក្នុងអាជីពរបស់ពួកគេមិនទាន់កើតនៅឡើយ។

កិច្ចខិតខំប្រឹងប្រែងដើម្បីផ្លាស់ប្តូរវិធីកុមាររៀននៅសតវត្សថ្មីគឺផ្អែកលើការសន្មត់ថា អ្នកអប់រំយល់ពីរបៀបដែលការផ្លាស់ប្តូរបែបនេះនឹងអាចជួយឱ្យកុមារអាចរស់នៅបានក្នុងសេដ្ឋកិច្ចថ្មី។ ឧទាហរណ៍ យុវជនម្នាក់នៅសតវត្សរ៍ទី ២១ ត្រូវរំពឹងថាអាចនឹងមានការផ្លាស់ប្តូរអាជីពពី ៣ ទៅ ៧ ដងក្នុងអំឡុងពេលនៃជីវិតរបស់ពួកគេ។ មិនដូចសតវត្សទី ២០ ឡើយដែលមនុស្សម្នាក់អាចរំពឹងថាគេមានតែអាជីពមួយសម្រាប់ពេញមួយជីវិតរបស់មនុស្សនោះ យុវជនក្នុងពិភពលោកបច្ចុប្បន្នត្រូវ 'រៀនដោយខ្លួនឯង' នៅពេលពួកគេផ្លាស់ប្តូរពីអាជីពមួយទៅអាជីពមួយក្នុងជីវិតរបស់ពួកគេ (សូមមើលប្រអប់ទី ២)។ ជាការពិតណាស់ ការងារជាច្រើននាពេលអនាគត មិនទាន់បានបង្កើតឡើងនៅឡើយទេ។



*ស្ថានភាពការងារពីអតីតកាលដែលផ្តោតសារៈសំខាន់លើអនុលោមភាព និង ភាពដូចគ្នា*

សម្រាប់អ្នកអប់រំ ដើម្បីបង្កើតការយល់ដឹងអំពីតម្រូវការសង្គមសតវត្សរ៍ទី២១ គឺត្រូវបោះបង់ចោលគំនិតនៅសតវត្សរ៍ទី ២០ នូវរបៀបដែលប្រព័ន្ធអប់រំផ្តល់ការអប់រំដល់កុមារ និងយុវជន ក៏ដូចជាការទទួលយកបញ្ញត្តិនៃការអប់រំនៅសតវត្សរ៍ទី ២១ ។ ក្នុងករណីជាច្រើន បញ្ញត្តិទាំងនេះគឺផ្ទុយស្រឡះពីសតវត្សមុន។ ក្នុងសតវត្សមុន សាលារៀនត្រូវបានកំណត់រចនាសម្ព័ន្ធដូចទៅនឹង 'រោងចក្រសិក្សា' ដោយផ្តោត

លើអនុលោមភាព និងជំនឿថាចំណេះដឹងភាគច្រើនអាចមាននៅក្នុងសៀវភៅសិក្សាគោលតែមួយ។ កាលពីមុន ចំណេះដឹងមានលក្ខណៈនឹងថ្កល់ ដែលធ្វើឱ្យសៀវភៅសិក្សាគោលត្រូវបានចាត់ទុកថាជាឃ្លាំងចំបងនៃចំណេះដឹងសម្រាប់ការរៀនក្នុងថ្នាក់។ សព្វថ្ងៃនេះចំណេះដឹងមានការផ្លាស់ប្តូរកាន់តែលឿន ធ្វើឱ្យមានការលំបាកសម្រាប់ការអានសៀវភៅដើម្បីបង្កើនចំណេះដឹង។ អាស្រ័យហេតុនេះហើយ បានជាតម្រូវឱ្យមានការសិក្សាតាមបែបបញ្ញត្តិ ដែលលើកទឹកចិត្តគ្រូបង្រៀនឱ្យបង្រៀនសិស្សលើសពីសៀវភៅសិក្សាគោល។

នៅក្នុងពិភពលោកកាលពីអតីតកាល កុមារត្រូវបានរៀបចំដើម្បីធ្វើការនៅកន្លែងការងារ ដែលផ្តោតសារៈសំខាន់លើលក្ខខណ្ឌការងារបែបឯកសណ្ឋានភាព និងបែបវិន័យ។ ក្នុងសតវត្សមុន លក្ខខណ្ឌនៃចំណេះដឹង និងការរៀបចំសេដ្ឋកិច្ចមានស្ថិរភាព ហើយការផ្លាស់ប្តូរមានភាពយឺតៗ ដូច្នោះហើយបានជាសាលារៀនមានភាពសមស្របដែលគួរផ្តោតលើការផ្ទេរចំណេះដឹង រៀបចំថ្នាក់រៀនបែបស្តង់ដា និងធ្វើតាមតែសៀវភៅសិក្សាគោល។ ទោះយ៉ាងណាក៏ដោយ បដិវត្តន៍ឌីជីថលបាននឹងកំពុងពន្លឿនយ៉ាងឆាប់រហ័សក្នុងអំឡុងសតវត្សទី ២១ ដែលនាំឱ្យមានការផ្លាស់ប្តូរវិធីបង្កើតចំណេះដឹង និងការរីកចម្រើនសេដ្ឋកិច្ច។ ក្នុងខណៈដែលមនុស្សយន្តកំពុងធ្វើការជំនួសមនុស្ស ការអប់រំត្រូវផ្តោតទៅលើការបង្កើតកម្លាំងការងារដែលម៉ាស៊ីនមិនអាចធ្វើបាន។ នេះមានន័យថា យើងត្រូវបង្កើតកម្លាំងការងារដែលចេះគិតបែបស៊ីជម្រៅ និងចេះសម្របខ្លួនបានយ៉ាងរហ័សទៅនឹងព្រំដែននៃចំណេះដឹង និងវិជ្ជាជីវៈដែលបាននឹងកំពុងផ្លាស់ប្តូរជានិច្ច។

ក្នុងខណៈដែលក្រសួងអប់រំ យុវជន និងកីឡា កំពុងលើកទឹកចិត្តគ្រូបង្រៀនឱ្យផ្លាស់ប្តូរការអនុវត្តការអប់រំរបស់ពួកគេ គ្រូបង្រៀនទាំងអស់ត្រូវមានការយល់ដឹង និងចេះពិចារណារក 'មូលហេតុ' ដែលនាំឱ្យមានការផ្លាស់ប្តូរទាំងនេះ។ ជារឿយៗ គ្រូបង្រៀនព្យាយាមទទួលយកវិធីសាស្ត្របង្រៀនថ្មីៗដោយមិនដឹងពី 'មូលហេតុ' ដែលពួកគេត្រូវធ្វើការផ្លាស់ប្តូរបែបនេះ (ក្រៅពីឆ្លើយថាក្រសួងបានតម្រូវឱ្យធ្វើបែបនេះ)។ ដូច្នេះ ការយល់ដឹងអំពីតម្រូវការនៃសតវត្សរ៍ទី២១ ជួយឱ្យគ្រូបង្រៀនយល់កាន់តែច្បាស់អំពី 'មូលហេតុ' ដែលក្រសួងចង់ឱ្យពួកគេផ្លាស់ប្តូរទៅរកវិធីសាស្ត្របង្រៀនដែលមានលក្ខណៈឌីណាមិកជាងមុន ងាកចេញពីការជំរុញកុមាររៀនបែបទន្ទេញចាំមាត់ ដែលស្របទៅនឹងការធ្វើការងារនៅក្នុង រោងចក្រសតវត្សរ៍ទី២០ ទៅរកវិធីសាស្ត្របង្រៀនដែលជួយកុមារឱ្យ "ចេះរៀនដោយខ្លួនឯង" ។ នៅពេលអានបញ្ញត្តិក្នុងប៉ារ៉ាម៉ែត្រនីមួយៗនៅក្នុងតារាងខាងក្រោម សូមពិចារណា ថាតើសាលារៀន ស្រុក ឬខេត្តរបស់អ្នកបានចាប់ផ្តើមផ្លាស់ប្តូរទៅរករចនាសម្ព័ន្ធអប់រំបែបសតវត្សទី ២១ ដល់កម្រិតណាហើយ។ សូមពិចារណាពីអ្វីដែលត្រូវបង្កើតឡើងនៅក្នុងមូលដ្ឋានរបស់អ្នក ដើម្បីធ្វើឱ្យសម្រេចបានតាមរចនាសម្ព័ន្ធថ្មីដែលបង្ហាញក្នុងតារាងខាងក្រោម។

### តារាងទី២.២៖ ភាពខុសគ្នារវាងរចនាសម្ព័ន្ធអប់រំបែបសតវត្សទី២០ និងសតវត្សទី២១

| ប៉ារ៉ាម៉ែត្រ | ការអប់រំសតវត្សទី២០ | ការអប់រំសតវត្សទី២១ |
|---|---|---|
| • បញ្ញត្តិនៃការរៀន | • ការផ្ទេរព័ត៌មាន<br>• ការរៀនបែបអកម្ម<br>• ការរៀនបែបទន្ទេញ | • សិស្សរៀនដោយខ្លួនឯង<br>• ការរៀនបែបសកម្ម<br>• ការរៀនបែបបញ្ញត្តិ |
| • កម្មវិធីសិក្សា | • រៀបជាស្តង់ដា<br>• ប្រើតែសៀវភៅសិក្សាគោល | • លក្ខណៈបុគ្គល<br>• រៀបចំបែបបញ្ញត្តិ<br>• បែបស្រាវជ្រាវ<br>• មិនប្រើតែសៀវភៅសិក្សាគោលមួយមុខនោះទេ |
| • ការវាយតម្លៃ | • ផ្ញើតែតេស្តវាយតម្លៃ | • ផ្តោតលើការបង្កើតកម្រងស្នាដៃ |
| • របៀបរៀបចំថ្នាក់រៀន | • រៀបជាស្តង់ដា<br>• របៀបរៀបចំគ្រឿងសង្ហារិមមិនប្រែប្រួល (ឧ. ជួរត្រង់) | • របៀបរៀបចំគ្រឿងសង្ហារិមប្រែប្រួល ឬ បត់បែន<br>• របៀបរៀបចំដែលបម្រើដល់ការងារក្រុម |
| • រចនាសម្ព័ន្ធសាលារៀន | • ឋានានុក្រម | • របៀបរៀបចំដែលជំរុញការបង្កើតជាបណ្តាញ និងការទំនាក់ទំនង |
| • ទស្សនវិជ្ជាអប់រំ | • អនុលោមភាព<br>• ភាពដូចគ្នា<br>• ឯកសណ្ឋានភាព | • ការរៀនបែបឌីណាមិក<br>• ការរៀនតាមរបៀបប្លែកៗគ្នា<br>• ការរៀនដែលជំរុញការបង្កើតថ្មី |
| • ស្ថាបត្យកម្មសាលារៀន | • ឯកសណ្ឋានភាព<br>• រៀបជាស្តង់ដា | • បែបឌីណាមិក<br>• មិនមានស្តង់ដា |

## សំណួរពិភាក្សា




*ការបង្រៀនបែបរ៉ាយរ៉ាប់ និងបែបផ្ទុះបញ្ចាំង*

១. តើអ្នកគិតថាការបង្រៀនបែបរ៉ាយរ៉ាប់នៅតែមានតួនាទីសំខាន់នៅក្នុងប្រទេសកម្ពុជាទេ? ហេតុអ្វី ឬហេតុអ្វីមិនសំខាន់?

២. តើអ្នកទទួលយកអំណះអំណាងដែលបានលើកឡើងខាងលើថា ការបង្រៀនបែបរ៉ាយរ៉ាប់មិនសមស្របនឹងការសិក្សាបែបបញ្ញត្តិឬទេ? ចូរពន្យល់ចម្លើយរបស់អ្នក។

៣. នៅក្នុងអត្ថបទខាងលើបានលើកឡើងថា ការបង្រៀនបែបឆ្លុះបញ្ចាំងគឺមិនមែនជាវិធីសាស្ត្របង្រៀនទេ ព្រោះវាមានលក្ខណៈជាដំណើរការច្រើនជាងសម្រាប់ការធ្វើផែនការបង្រៀនមួយដែលអាចយកទៅអនុវត្តជាមួយវិធីសាស្ត្រណាមួយក៏បាន។ តើអ្នកយល់ស្របនឹងភាពខុសគ្នារវាង 'ដំណើរការ' នៃការបង្រៀន និង 'វិធីសាស្ត្រ' នៃការបង្រៀននេះឬទេ? ហេតុអ្វីឬហេតុអ្វីមិនយល់ស្រប?

៤. តើអ្នក (ឧ. អ្នកដឹកនាំសាលា គ្រូប្រឹក្សាគរុកោសល្យ ។ល។) គិតថាត្រូវមានលក្ខខណ្ឌអ្វីខ្លះសម្រាប់សាលារៀនដើម្បីជំរុញការសិក្សាបែបឆ្លុះបញ្ចាំង?

### *ការអប់រំបែបសតវត្សទី២១*

១. ហេតុអ្វីបានជាអ្នកគិតថា ការសិក្សាបែបបញ្ញត្តិ មិនសមស្របជាមួយនឹងការរៀនដែលផ្តោតតាមតែសៀវភៅសិក្សាគោល? តើអ្នកយល់ស្របនឹងសំណើនេះឬទេ? ចូរពន្យល់ចម្លើយរបស់អ្នក។

២. ប្រសិនបើប្រទេសកម្ពុជាមិនបានកែប្រែប្រព័ន្ធអប់រំរបស់ខ្លួនស្របទៅនឹងតម្រូវការរបស់សង្គមសតវត្សទី២១ តើអ្នកគិតថាវានឹងប៉ះពាល់ដល់ព្រះរាជាណាចក្រនេះយ៉ាងដូចម្តេច? សូមផ្តល់ឧទាហរណ៍បញ្ជាក់។

៣. តើអ្នកអាចផ្តល់ឧទាហរណ៍ជាក់ស្តែងនៃប៉ារ៉ាម៉ែត្រនីមួយៗសម្រាប់ការអប់រំសតវត្សទី ២១ ដែលបានពិពណ៌នានៅក្នុងតារាង ២.២ ខាងលើបានឬទេ? តើតំបន់របស់អ្នកបានអនុវត្តដល់កម្រិតណាដើម្បីសម្រេចបាននូវការផ្លាស់ប្តូរទាំងនេះ?

## អំណានបន្ថែម




1. Serra, R., (2015) *What Is Reflective Teaching and Why Is It Important?* Richmond Share Blog.

https://www.richmondshare.com.br/what-is-reflective-teaching-and-why-is-it-important/

2. Theara, K. (2020) *Education: Pedagogy and Infrastructure (Chapter 4),* in Cambodia 2040: Culture & Society, Phnom Penh: Adenauer Foundation.

https://www.kas.de/documents/264850/9494366/Cambodia+2040+Culture+and+Society.pdf/2d86a754-1708-ca31-d78f-e70ac7b19aac?version=1.0&t=1593966925445

3. MoEYS (2019) *Transitions in Education: Moving from the 20th to the 21st* Century (PowerPoint Presentation).

4. *What is 21st Century Education* (Video)

*https://www.youtube.com/watch?v=Ax5cNlutAys*

5. *What is 21st Century Education: What Should 21st Century Learning Consist of?* (Video)

https://www.youtube.com/watch?v=ypSNpiW2qRs

# ៣. ភាពខុសគ្នារវាង គោលវិធី វិធីសាស្ត្រ និង ល្បិច បង្រៀន

## ៣.១ ការពន្យល់ទំនាក់ទំនងរវាងគោលវិធី វិធីសាស្ត្រ និងល្បិច

ជាច្រើនឆ្នាំមកនេះ អ្នកអប់រំកម្ពុជាបានស្វែងរកការរៀបចំជាប្រព័ន្ធ និងស្តង់ដានូវការប្រើប្រាស់វាក្យសព្ទ និងបញ្ញត្តិផ្សេងៗ។ ជាពិសេសស ការពិភាក្សាអំពីភាពខុសប្លែកគ្នារវាងគោលវិធី វិធីសាស្ត្រ និងល្បិច បង្រៀន។ ជាថ្មីម្តងទៀត ការពិភាក្សាបែបនេះ ឆ្លុះបញ្ចាំងពីដំណើរស្វែងការយល់ដឹងត្រឹមត្រូវឥតខ្ចោះ (orthodoxy) ផ្នែកវិធីសាស្ត្របង្រៀនដែលជាគ្រោះថ្នាក់មួយដូចដែលយើងបានពិភាក្សារួចហើយ។ យ៉ាងណាក៏ដោយ ការកំណត់ពាក្យបច្ចេកទេសមួយចំនួនតាមវិធីសាមញ្ញអាចមានប្រយោជន៍ ហើយពិតជាអាចការពារការខ្វែងគំនិតគ្នាបាន។ គោលបំណងសំខាន់គឺចង់ឱ្យមនុស្សគ្រប់គ្នាអាចយល់ស្របគ្នាលើឋានានុក្រមទូទៅនៃប្រព័ន្ធអប់រំ។

*រូបភាព៣.១ ទំនាក់ទំនងតាមឋានានុក្រមរវាងគោលវិធី វិធីសាស្ត្រ និង ល្បិច*




ក្នុងកម្រិតអន្តរជាតិ អ្នកអប់រំកំណត់ពាក្យ 'គោលវិធី' ថាជាកម្រិតខ្ពស់បំផុតនៃប្រព័ន្ធគំនិតអប់រំ។ នៅក្នុងក្របខណ្ឌដែលបង្ហាញក្នុងរូបភាព ៣.១ យើងកំណត់និយមន័យ **គោលវិធី** ថាជាទស្សនវិជ្ជានៃការបង្រៀន និងរៀន (ឧ. ការសិក្សាបែបស្ថាបនានិយម វឌ្ឍនភាពនិយម។ល។)។ គោលវិធីទស្សនវិជ្ជា បង្កប់នូវគោលការណ៍បែបអរូបី ដែលជាមគ្គុទ្ទេសសម្រាប់ឈានទៅអភិវឌ្ឍវិធីសាស្ត្រ (សូមមើល **ឧបសម្ព័ន្ធទី ១៖** បញ្ជីទ្រឹស្តីទស្សនវិជ្ជាក្នុងការអប់រំ)។ នៅក្នុងគោលវិធីមួយ អាចមាន**វិធីសាស្ត្រ**ជាច្រើននៅក្នុងនោះ (ឧ. IBL, PBL, ។ល។) ហើយនៅក្នុង វិធីសាស្ត្រ អាចមាន**ល្បិច** បង្រៀនជាច្រើន។

*រូបភាព ៣.២៖ ឧទាហរណ៍អំពី គោលវិធី វិធីសាស្ត្រ និងល្បិច បង្រៀន ក្នុងឋានានុក្រមប្រព័ន្ធអប់រំ*




និយមន័យស្តង់ដានៃពាក្យ គោលវិធី វិធីសាស្ត្រ និងល្បិច បង្រៀន មានផ្តល់ជូននៅក្នុងប្រអប់ទី៣។ ចំណុចសំខាន់ដែលត្រូវកត់សម្គាល់នោះគឺ នៅពេលផ្លាស់ប្តូរពី គោលវិធី ទៅ ល្បិច គឺមានន័យថា ជាការផ្លាស់ទីពីគោលការណ៍អរូបី ទៅរកដំណើរការ បំណិន និងសកម្មភាពជាក់ស្តែង។ លើសពីនេះ គោលវិធីខ្លះ គេបានបង្កើតទៅជា វិធីសាស្ត្រ ជាច្រើនដែលវិធីសាស្ត្រនីមួយៗបានធ្វើការការបកស្រាយខុសៗគ្នាទៅលើគោលវិធីដូចគ្នា។ ឧទាហរណ៍ ក្នុងតារាង ៣.១ ខាងក្រោម បានពិពណ៌នាវិធីសាស្ត្របីផ្សេងគ្នាដែលវិធីសាស្ត្រនីមួយៗបង្ហាញឧទាហរណ៍អំពីគោលវិធីអប់រំ 'បែបស្ថាបនានិយម' ។ ដូច្នោះយើងឃើញហើយថា ល្បិចបង្រៀន ដែលឱ្យ 'សិស្សធ្វើបទបង្ហាញ' ត្រូវបានគេប្រើប្រាស់ជាទូទៅនៅក្នុងវិធីសាស្ត្រការសិក្សាបែបគម្រោង ការសិក្សាបែបរិះរក និងការសិក្សាអាស្រ័យលើបញ្ហា។

**ប្រអប់ទី៣៖ និយមន័យនៃគោលវិធីអប់រំ វិធីសាស្ត្រ និងល្បិច**

**គោលវិធីអប់រំ** គឺជាទស្សនវិជ្ជានៃការបង្រៀន និងការរៀន ដែលមានគោលការណ៍បែបអរូបី ដែលជាមគ្គុទ្ទេសនាំទៅការអភិវឌ្ឍវិធីសាស្ត្របង្រៀនជាក់លាក់។

**វិធីសាស្ត្រអប់រំ** គឺជាប្រព័ន្ធនៃល្បិច ការអនុវត្ត និងដំណើរការ ដែលគ្រូប្រើដើម្បីបង្រៀន។ វិធីសាស្ត្របង្កើតឡើងដោយផ្អែកលើទ្រឹស្តីទស្សនវិជ្ជាជាក់លាក់ចំពោះការបង្រៀន និងការរៀន។

**ល្បិចអប់រំ** គឺជាបំណិន និងសកម្មភាពជាក់លាក់ដែលគ្រូប្រើ (ឧ. ការសួរសំណួរ កាចាត់តាំងគម្រោងឱ្យសិស្ស ការរៀបចំសិស្សជាក្រុម។ល។) ដែលជាផ្នែកមួយនៃវិធីសាស្ត្រទូលំទូលាយ។

## តារាង ៣.១៖ ការប្រើប្រាស់ប្រព័ន្ធឋានានុក្រមថ្មីដើម្បីពន្យល់ទំនាក់ទំនងរវាងគោលវិធី វិធីសាស្ត្រ និងល្បិចបង្រៀនក្នុងបរិបទការសិក្សាបែបស្ថាបនានិយម

| គោលវិធី (ឬ ទស្សនវិជ្ជា) | គំរូវិធីសាស្ត្រ | ល្បិចបង្រៀនទាក់ទងនឹងវិធីសាស្ត្រ |
|---|---|---|
| ស្ថាបនានិយម៖<br><br>ស្ថាបនានិយម គឺជា "គោលវិធីសិក្សាដែលធ្វើឱ្យសិស្សស្ថាបនា ឬបង្កើតចំណេះដឹងផ្ទាល់ខ្លួន ហើយចំណេះដឹងពិត ត្រូវបានកំណត់ផ្អែកលើបទពិសោធន៍របស់សិស្ស" | **វិធីសាស្ត្រការសិក្សាបែបគម្រោង** តម្រូវឱ្យសិស្សដោះស្រាយបញ្ហាជាក់ស្តែងក្នុងរយៈពេលមួយ ដោយបង្កើតគម្រោងផ្ទាល់ខ្លួនរបស់ពួកគេ។ គម្រោងនេះអាចត្រូវបានស្នើឡើងដោយគ្រូ ប៉ុន្តែសិស្សជាអ្នកគ្រោងផែនការ និងប្រតិបត្តិដោយផ្ទាល់ ដែលអាចជាលក្ខណៈបុគ្គល ឬជាក្រុម។ | • ការកំណត់គម្រោង<br>• សិស្សធ្វើការជាក្រុម<br>• សិស្សស្រាវជ្រាវ<br>• សិស្សធ្វើបទបង្ហាញ |
| | **វិធីសាស្ត្រសិក្សាបែបរិះរក** គឺជាទម្រង់នៃការរៀនបែបសកម្មដែលចាប់ផ្តើមដោយការសួរសំណួរ បញ្ហា ឬសេណារីយ៉ូ។ វិធីសាស្ត្រនេះ ផ្ទុយនឹងការអប់រំបែបប្រពៃណី ដែលជាទូទៅសិស្សពឹងផ្អែកលើគ្រូបង្ហាញអង្គហេតុ និងចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគេអំពីប្រធានបទ។ | • សិស្សកំណត់សំណួរដែលពួកគេចង់រកចម្លើយ<br>• សិស្សស្រាវជ្រាវ<br>• សិស្សធ្វើបទបង្ហាញ<br>• សិស្សធ្វើការឆ្លុះបញ្ចាំង លើដំណើរការដែលល្អនិងមិនល្អ |
| | **វិធីសាស្ត្រសិក្សាអាស្រ័យលើបញ្ហា** គឺជាវិធីសាស្ត្របង្រៀនដែលគេយកបញ្ហាក្នុងពិភពពិតជាក់ស្តែងធ្វើជាមធ្យោបាយដើម្បីលើកកម្ពស់ការសិក្សារបស់សិស្សអំពីបញ្ញត្តិ និងគោលការណ៍ ដែលផ្ទុយពីការបង្ហាញដោយផ្ទាល់នូវអង្គហេតុ និងបញ្ញត្តិ។ | • ជំហានទី ១៖ ស្វែងយល់ និងកំណត់បញ្ហា<br>• ជំហានទី ២៖ សិស្សនិយាយពីអ្វីដែលពួកគេបានដឹង...<br>• ជំហានទី ៣៖ សិស្សកំណត់និយមន័យបញ្ហា ...<br>• ជំហានទី ៤៖ សិស្សស្រាវជ្រាវចំណេះដឹង ...<br>• ជំហានទី ៥៖ ស៊ើបអង្កេតរកដំណោះស្រាយ ...<br>• ជំហានទី ៦៖ បង្ហាញ និងគាំទ្រដំណោះស្រាយដែលបានរកឃើញ ...<br>• ជំហានទី ៧៖ សិស្សត្រួតពិនិត្យលទ្ធផលការងារពួកគេឡើងវិញ។ |

**ប្រអប់ទី៤៖ តើអ្វីជាយុទ្ធសាស្ត្រអប់រំ?**
យុទ្ធសាស្ត្រអប់រំសំដៅលើសកម្មភាពជាក់លាក់ដែលគ្រូអាចរៀបចំផែនការដើម្បីដោះស្រាយលក្ខណៈពិសេសជាក់លាក់នៃបរិបទសិក្សា។ លក្ខណៈពិសេសទាំងនេះអាចរួមមានបរិយាកាសសិក្សាជាក់ស្តែង ចរិតលក្ខណៈរបស់សិស្ស និង/ឬធម្មជាតិនៃខ្លឹមសារកម្មវិធីសិក្សាដែលត្រូវបង្រៀន។

ទោះជាយ៉ាងណាក៏ដោយ គេគួរតែចងចាំថា ប្រភេទ និងនិយមន័យទាំងនេះគ្រាន់តែជាឧបករណ៍បកស្រាយត្រួសៗ ដើម្បីជួយយើងឱ្យយល់ពីគំនិតផ្សេងៗគ្នា ថាមានភាពទាក់ទងគ្នាទៅវិញទៅមករបៀបណា។ នៅក្នុងជីវិតជាក់ស្តែង គ្រូបង្រៀនកម្រនឹងប្រើគោលវិធីមួយ ឬវិធីសាស្ត្រតែមួយគ្រប់ពេលវេលានោះឡើយ។ ជារឿយៗ គេរំពឹងឱ្យគ្រូបង្រៀនចេះបញ្ចូលគ្នានូវធាតុផ្សំផ្សេងៗគ្នានៃគោលវិធី និងវិធីសាស្ត្រផ្សេងៗគ្នាដោយអាស្រ័យលើបរិបទ។ គ្រូបង្រៀនជារឿយៗធ្វើសកម្មភាពជាក់លាក់ដោយបញ្ចូលគ្នា និង/ឬកែប្រែគោលវិធី/វិធីសាស្ត្រ ដើម្បីដោះស្រាយឧបសគ្គជាក់លាក់នៅក្នុងថ្នាក់រៀនរបស់ពួកគេ។ នៅពេលគ្រូបង្រៀនចេះធ្វើបែបនេះ នោះបានន័យថា ពួកគេចេះបង្កើតយុទ្ធសាស្ត្រ បង្រៀន (សូមមើលប្រអប់ទី ៤)។

គ្រូអាចប្រើយុទ្ធសាស្ត្រផ្សេងៗនៅពេលបង្រៀន ដោយផ្អែកលើលក្ខណៈជាក់លាក់នៃបរិបទសិក្សាជាក់ស្តែងដែលពួកគេកំពុងបង្រៀន (ឧ. ថ្នាក់រៀនដែលមានសិស្សច្រើន បរិយាកាសសិក្សាដែលខ្វះសម្ភារៈបង្រៀន ។ល។) ប្រភេទសិស្សដែលពួកគេកំពុងបង្រៀន (ឧ. ថ្នាក់រៀនដែលមានសិស្សដែលមានសមត្ថភាពសំយោគ) ឬប្រភេទនៃកម្មវិធីសិក្សាដែលពួកគេត្រូវបង្រៀន (ឧ. ខ្លឹមសារផ្អែកលើសៀវភៅសិក្សាគោល ខ្លឹមសារបែបអេឡិចត្រូនិក។ល។)។ យុទ្ធសាស្ត្របង្រៀន មិនមែនជាប្រព័ន្ធអប់រំទេ ប៉ុន្តែជាសកម្មភាពជាក់លាក់ដែលគ្រូបង្រៀនបង្កើតឡើងដោយរួមបញ្ចូលគ្នានូវគំនិតសំយោគពីគោលវិធី វិធីសាស្ត្រ ឬល្បិចច្រើនបែប។

## សំណួរពិភាក្សា

១. តើឋានានុក្រមនៃទស្សនវិជ្ជា និងប្រព័ន្ធអប់រំដែលបង្ហាញក្នុងឯកសារនេះ ជួយអ្នកឱ្យចេះរៀបចំវិធីសាស្ត្របង្រៀនខុសៗគ្នាបែបសមហេតុផលបានដែរឬទេ? សូមពន្យល់ចម្លើយរបស់អ្នក។

២. វិធីសាស្ត្របង្រៀនផ្សេងៗគ្នាជាច្រើនដែលប្រើក្នុងប្រទេសកម្ពុជា (ឧ. IBL, PBL ។ល។) ហាក់ដូចជាមានទំនាក់ទំនងបែបប្រកួតប្រជែងជាមួយគ្នាទៅវិញទៅមកក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ។ តើឋានានុក្រមអប់រំដែលបានបង្ហាញខាងលើជួយឱ្យមានភាពសុខដុមកាន់តែប្រសើរឡើងរវាងវិធីសាស្ត្រទាំងនេះ (ជាពិសេសប្រសិនបើយើងពិចារណាថាពួកវាកើតចេញពីគោលវិធីអប់រំតែមួយ) ឬទេ? សូមពន្យល់ចម្លើយរបស់អ្នក។

៣. តើគោលវិធីអប់រំ ឬទស្សនវិជ្ជាប៉ុន្មានដែលអ្នកដឹង? តើអ្នកអាចរាយបញ្ជីពួកវា ហើយធ្វើតារាងដែលបង្ហាញពីរបៀបដែលដូចគ្នា និងខុសគ្នាបានដែរឬទេ?

៤. តើអ្នកអាចគិតពីវិធីសាស្រ្តបង្រៀនផ្សេងទៀតដែលកើតចេញពី គោលវិធីសិក្សាបែបស្ថាបនានិយម ក្រៅពីអ្វីដែលបានរៀបរាប់រួចហើយ? ប្រសិនបើអ្នកអាចធ្វើបាន សូមព្យាយាមពង្រីកតារាងដែលបានផ្តល់ខាងលើដោយបន្ថែមវិធីសាស្រ្ត និងល្បិចបង្រៀន ដែលអ្នកអាចគិតឃើញ។

## អំណានបន្ថែម




1. Namoco, S. (2017) Teaching Approaches, Methods, Techniques, and Strategies (YouTube Presentation). https://www.youtube.com/watch?v=1xGmK_AJPNQ
2. Rhalmi, M. (2018) *Approach, Method, Procedure, and Technique,* in 'Reflections in New Teaching Horizons.' https://www.myenglishpages.com/blog/approach-method-procedure-and-technique/
3. Bas, A., *The Seven Philosophies of Education: What to Teach, Why to Teach, and How to Teach.* Academia.edu https://www.academia.edu/36818346/The_Seven_Philosophies_of_Education_Philosophy_Why_Teach_What_to_Teach_How_to_Teach

# ៤. ការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីគរុកោសល្យ ដើម្បីបង្កើនប្រសិទ្ធភាពនៃវិធីសាស្ត្របង្រៀនថ្មី

## ៤.១ និយមន័យប្រព័ន្ធអេកូឡូស៊ីការសិក្សា

ការតស៊ូមតិដើម្បីឱ្យគ្រូបង្រៀនផ្លាស់ប្តូរការអនុវត្តការបង្រៀនរបស់ពួកគេ និងដើម្បីទទួលយកវិធីសាស្ត្របង្រៀនបន្ថែមទៀតស្របតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា (ឧ. ការសិក្សាបែបបញ្ញត្តិ ការសិក្សាផ្អែកលើបញ្ហា។ល។) មិនអាចកើតឡើងដោយមិនគិតអំពីឥទ្ធិពលផ្សេងៗនោះទេ។ មានកត្តាជាច្រើននៅក្នុងបរិយាកាសរបស់សាលារៀនដែលអាចលើកកម្ពស់ ឬរារាំងការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាពក្នុងការអនុវត្តការបង្រៀន។ គំនិតនេះនាំទៅរកការប្រៀបធៀបបរិយាកាសសិក្សានៅក្នុងសាលារៀនទៅនឹងប្រព័ន្ធដែលគេហៅថា 'ប្រព័ន្ធអេកូឡូស៊ី' (មើលប្រអប់ទី៥ និង ៦)។ នៅក្នុងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ មានការអាស្រ័យគ្នាទៅវិញទៅមកយ៉ាងខ្លាំងរវាងសត្វ និងរុក្ខជាតិ និងបរិយាកាសរូបវន្តរបស់វា។ ការផ្លាស់ប្តូរយ៉ាងខ្លាំងនៃអ្វីមួយនៅក្នុងចំណោមរបស់ទាំងនេះនឹងជះឥទ្ធិពលទៅលើអ្វីផ្សេងទៀត ដោយសារតែវាមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ជាឧទាហរណ៍ ការកាប់ដើមឈើអាចបណ្តាលឱ្យមានសំណឹកដែលបំពុលទឹកអូរ និងបឹង។ នៅពេលដែលប្រភពទឹកទាំងនេះក្លាយជាការបំពុល ត្រី និងសត្វក្នុងទឹកផ្សេងទៀតនឹងស្លាប់។ បញ្ហានេះនាំទៅការកាត់បន្ថយបរិមាណអាហារដែលអាចរកបានសម្រាប់សត្វដែលរស់នៅលើដី ហើយក៏នាំទៅការកាត់បន្ថយចំនួនសត្វទាំងនេះជាបន្តបន្ទាប់។ ឧទាហរណ៍ដ៏សាមញ្ញនេះបង្ហាញពីរបៀបមួយដែលថារាល់ការផ្លាស់ប្តូររបស់ជាតុមួយនៅក្នុងប្រព័ន្ធអេកូឡូស៊ីនឹងបង្កឱ្យមានប្រតិកម្មជាខ្សែសង្វាក់ប៉ះពាល់ដល់ជាតុផ្សេងទៀតទាំងអស់។

**ប្រអប់ទី ៥៖ តើប្រព័ន្ធអេកូឡូស៊ីជាអ្វី?**
ប្រព័ន្ធអេកូឡូស៊ី គឺជាប្រព័ន្ធមួយដែលធាតុរបស់វាមានអន្តរទំនាក់ទំនងគ្នា ដែលបង្កើតឡើងដោយអន្តរកម្មរវាងសហគមន៍អង្គភាព និងបរិស្ថានរបស់ពួកគេ។

**ប្រអប់ទី ៦៖ ការប្រៀបធៀបសាលារៀនទៅនឹងប្រព័ន្ធអេកូឡូស៊ី**
ប្រសិនបើយើងជឿថាសាលារៀនគឺជាប្រព័ន្ធអេកូឡូស៊ី ហើយធ្វើសកម្មភាពតាមប្រព័ន្ធបែបនោះ នោះយើងនឹងផ្លាស់ប្តូរទស្សនៈរបស់យើង។ យើងដឹងថាគ្រប់ធាតុរបស់សាលារៀនមានឥទ្ធិពលទៅលើផ្នែកផ្សេងទៀត។
(Edutopia, 2016)

តាមរយៈការប្រៀបធៀបទៅនឹងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ អ្នកអប់រំអាចគិតទៅលើ 'ប្រព័ន្ធអេកូឡូស៊ីគរុកោសល្យ' ដែលរួមមានធាតុជាច្រើន (ឧ. ឪពុកម្តាយ សហគមន៍ គ្រឿងបរិក្ខាររូបវន្ត ។ល។ សូមមើលរូបភាព ៤.១)។ ការយល់ដឹងពីរបៀបដែលធាតុទាំងនេះអន្តរកម្មជាមួយគ្នា នឹងជួយអ្នករៀបចំផែនការឱ្យយល់កាន់តែច្បាស់អំពីរបៀបបង្កើនប្រសិទ្ធភាពការអនុវត្តការបង្រៀននៅក្នុងសាលារៀន។ ជាឧទាហរណ៍ មានកត្តាជាច្រើននៅក្នុងសាលាដែលអាចកាត់បន្ថយកិច្ចខិតខំប្រឹងប្រែងលើការផ្លាស់ប្តូរការអនុវត្តការបង្រៀនរបស់គ្រូ បើទោះបីជាយើងបណ្តាក់ទុនយ៉ាងច្រើននៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលក៏ដោយ។ កត្តាទាំងនេះរួមមានភាពជាអ្នកដឹកនាំសាលារៀនមិនល្អ វប្បធម៌ជំរុញដោយ

ការធ្វើតេស្ត គ្មានការគាំទ្រផ្នែកប្រឹក្សាគរុកោសល្យ កង្វះសហគមន៍សិក្សាវិជ្ជាជីវៈគ្រូ (និងកង្វះការចែករំលែក) ជាដើម។ (សូមមើលរូបភាព ៤.២)។ តារាង ៤.២ ខាងក្រោមផ្តល់នូវការពន្យល់ខ្លះអំពីកត្តារាំងស្ទះនៅក្នុងប្រព័ន្ធអេកូឡូស៊ីគរុកោសល្យ ដែលផ្តល់ផលប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងជួយគ្រូបង្រៀនឱ្យទទួលយកវិធីសាស្រ្តថ្មីដើម្បីជំរុញការសិក្សាតាមបែបបញ្ញត្តិ។

### តារាង ៤.១៖ ការពន្យល់ពីអន្តរកម្មរវាងធាតុនៅក្នុងប្រព័ន្ធអេកូឡូស៊ីគរុកោសល្យ

| កត្តាទាក់ទងនឹងប្រព័ន្ធអេកូឡូស៊ី | របៀបដែលកត្តាទាំងនេះអាចធ្វើឱ្យខូចដល់ការទទួលយកវិធីសាស្រ្តបង្រៀនថ្មី |
|---|---|
| • ភាពជាអ្នកដឹកនាំអន់ | នាយកសាលាអាចផ្តោតតែលើការធ្វើឱ្យមនុស្សគ្រប់គ្នាសប្បាយចិត្ត ជាជាង 'ហ៊ានប្រថុយធ្វើអ្វីហួសពីកម្រិតធម្មតា' ដើម្បីកែលម្អសាលារៀន ឬ ធានាថាគ្រូបង្រៀន/សិស្សកំពុងប្រើប្រាស់បណ្ណាល័យ។ល។ |
| • វប្បធម៌បង្រៀនដែលជំរុញដោយការធ្វើតេស្ត | គ្រូបង្រៀនផ្តោតយ៉ាងខ្លាំងលើ 'ការបង្រៀនដើម្បីតែការប្រឡង' ដែលបង្កើតឧបសគ្គចំពោះការជំរុញវិធីសាស្រ្តបង្រៀនថ្មីដើម្បីលើកកម្ពស់ការគិតបែបស៊ីជម្រៅ។ |
| • វប្បធម៌សិក្សាដែលប្រើតែសៀវភៅសិក្សាគោល | គ្រូបង្រៀនផ្តោតតែលើអ្វីដែលមាននៅក្នុងសៀវភៅសិក្សាគោល ជាជាងផ្តល់ឱ្យសិស្សនូវ 'រូបភាពធំ' អំពីការស្វែងរកចំណេះដឹងថ្មីៗដែលមានប្រយោជន៍សម្រាប់ជីវិតប្រចាំថ្ងៃរបស់សិស្ស។ |
| • កង្វះការចែករំលែកក្នុងចំណោមគ្រូ | គ្រូបង្រៀនដែលផ្តោតតែលើការបង្រៀនឯកជន អាចនឹងមិនចែករំលែកល្បិចបង្រៀន និងឯកសារមានប្រយោជន៍ជាមួយគ្រូផ្សេងទៀត។ |
| • កង្វះការគាំទ្រផ្នែកប្រឹក្សាគរុកោសល្យ | គ្រូបង្រៀនមិនទទួលបានការផ្តល់ប្រឹក្សាគរុកោសល្យអំពីរបៀបអនុវត្តវិធីសាស្រ្តបង្រៀនថ្មីដែលស្របទៅនឹងតម្រូវការជាក់លាក់របស់សិស្ស និងថ្នាក់រៀនរបស់ពួកគេឡើយ។ |

*រូបភាពទី ៤.១៖ ការពិពណ៌នាពីប្រព័ន្ធអេកូឡូស៊ីគរុកោសល្យនៅក្នុងសាលារៀនទំនើប*



ការអភិវឌ្ឍវិស័យអប់រំមានទំនោរខ្លាំងលើការវិនិយោគក្នុងសិក្ខាសាលាបណ្តុះបណ្តាលវិធីសាស្ត្របង្រៀន ហើយមានការយកចិត្តទុកដាក់តិចតួចលើការបង្កើតបរិយាកាសអំណោយផលដើម្បីជំរុញការផ្លាស់ប្តូរ ដែលនេះហើយជាមូលហេតុនាំឱ្យការផ្លាស់ប្តូរការអនុវត្តការបង្រៀននៅក្នុងប្រទេសកម្ពុជាមានភាពយឺតយ៉ាវ។ ដូច្នេះហើយ គំនិតថ្មីអំពីសាលារៀនដែលលើកទឹកចិត្តអ្នកអប់រំឱ្យពិនិត្យមើលការផ្លាស់ប្តូរការអនុវត្តការបង្រៀន ដែលជាផ្នែកមួយនៃប្រព័ន្ធអេកូឡូស៊ី អាចជួយធានាថាប្រទេសកម្ពុជាអនុវត្តការផ្លាស់ប្តូរការអនុវត្តការបង្រៀនកាន់តែមានប្រសិទ្ធភាព។




*រូបភាពទី ៤.២៖ អន្តរកម្មរវាងកត្តាដែលរាំងស្ទះដល់ការទទួលយកវិធីសាស្ត្រសិក្សាថ្មី*

## ៤.២ របៀបដែលសាលារដ្ឋអាចរៀនពីប្រព័ន្ធអេកូឡូស៊ីគរុកោសល្យនៅក្នុងសាលារៀនជំនាន់ថ្មី

ʹ កំណែទម្រង់ថ្មីៗនេះនៅក្នុងប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាដែលបានបង្កើតសាលាជំនាន់ថ្មីផ្តល់នូវបទពិសោធន៍យ៉ាងច្រើនអំពីការកែប្រែប្រព័ន្ធអេកូឡូស៊ីគរុកោសល្យរបស់សាលាដើម្បីពង្រីកការផ្លាស់ប្តូរក្នុងការអនុវត្តការបង្រៀន។ កិច្ចប្រឹងប្រែងទាំងនេះ ចាប់ផ្តើមដំបូង និងសំខាន់បំផុតលើការកសាងភាពជាអ្នកដឹកនាំដ៏ល្អក្នុងចំណោមអ្នកគ្រប់គ្រងសាលាដែលជាហេតុនាំឱ្យមានការតស៊ូមតិយ៉ាងសកម្មឱ្យគ្រូបង្រៀនប្រើប្រាស់ធនធានសាលាឱ្យកាន់តែប្រសើរឡើង។ ការតស៊ូមតិនេះនាំឱ្យមានការប្រើប្រាស់បណ្ណាល័យសាលាកាន់តែប្រសើរឡើង (សម្រាប់សិស្សស្រាវជ្រាវ) និងសម្ភារៈបរិក្ខារថ្មីដែលផ្តល់ជូននៅក្នុងថ្នាក់រៀន និងបន្ទប់ពិសោធន៍ (សូមមើលរូបភាព ៤.៣)។ អ្នកគ្រប់គ្រងសាលារៀនក៏បានជំរុញការប្រើប្រាស់បច្ចេកវិទ្យាយ៉ាងសកម្ម ដែលជាផ្នែកមួយដ៏សំខាន់សម្រាប់គ្រប់គ្រងសាលា រួមទាំងជាមធ្យោបាយដល់គ្រូបង្រៀនបញ្ជូនផែនការមេរៀនតាមអេឡិចត្រូនិកសម្រាប់ផ្តល់ព័ត៌មានត្រឡប់ និងការពិភាក្សាគ្នាក្នុងអំឡុងពេលជួបផ្ទាល់មួយទល់មួយជាមួយគ្រូប្រឹក្សាគរុ

*រូបភាព ៤.៣៖ ការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធអេកូឡូស៊ីគរុកោសល្យនៅសាលារៀនជំនាន់ថ្មី*




**ប្រអប់ទី ៧៖ ការស្រាវជ្រាវអំពីរបៀបដែលគ្រូបង្រៀនផ្លាស់ប្តូរការអនុវត្តរបស់ពួកគេ៖ គំរូ ៧០-២០-១០**

គំរូ ៧០-២០-១០ គឺជារូបមន្តដែលត្រូវបានគេទទួលយកយ៉ាងល្អនៅក្នុងវិជ្ជាជីវៈបណ្តុះបណ្តាល។ គំរូនេះបានដកស្រង់ចេញពីការស្រាវជ្រាវរបស់សហរដ្ឋអាមេរិកក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ លើប្រភពសំខាន់ៗនៃការសិក្សារបស់អ្នកគ្រប់គ្រងជោគជ័យចំនួន ២០០នាក់ ។

*លទ្ធផលបង្ហាញថា៖*

- **៧០%** នៃការរៀនសូត្របានមកពីបទពិសោធន៍ធ្វើផ្ទាល់ ដែលកម្មករបានជួបបញ្ហាប្រឈមទាក់ទងនឹងការងារ និងទទួលបានមតិកែលម្អភ្លាមៗអំពីការអនុវត្តរបស់ពួកគេពីអ្នកគ្រប់គ្រងផ្ទាល់ និង គ្រូប្រឹក្សាគរុកោសល្យ។
- **២០%** នៃការរៀនសូត្របានមកពីការប្រាស្រ័យទាក់ទង និងការសហការជាមួយសហការីផ្សេងទៀត គ្រូបង្វឹក និង គ្រូប្រឹក្សាគរុកោសល្យដែលផ្តល់ការលើកទឹកចិត្ត និងមតិកែលម្អ។
- មានតែ **១០%** នៃការអភិវឌ្ឍវិជ្ជាជីវៈបានមកពីការបណ្តុះបណ្តាលបែបប្រពៃណី និងព្រឹត្តិការណ៍អប់រំផ្សេងៗទៀត។

នៅពេលរួមបញ្ចូលគ្នាជាមួយនឹងការបណ្តុះបណ្តាលផ្លូវការ ការបង្វឹក និងការពង្រឹងការអនុវត្ត អាចបង្កើតលទ្ធផលគួរឱ្យកត់សម្គាល់។ យោងតាមមជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រង និងប្រសិទ្ធភាពស្ថាប័ន (CMOE)ពង្វាញថា **ការរួមបញ្ចូលគ្នានូវការបណ្តុះបណ្តាល បូកនឹងការបង្វឹក អាចនាំទៅដល់ការបង្កើនផលិតភាពដល់ ៨៨%** ធៀបនឹង ២៣% ពីការបណ្តុះបណ្តាលតែឯង។

កោសល្យ។ គ្រូប្រឹក្សាគរុកោសល្យទាំងនេះត្រូវបានតែងតាំងទៅក្នុងសាលារៀនជាអចិន្ត្រៃយ៍ ដើម្បីជួយអ្នកគ្រប់គ្រងសាលា ក្នុងការគាំទ្រគ្រូបង្រៀនឱ្យទទួលយកវិធីសាស្ត្របង្រៀនថ្មី ដែលជាទូទៅផ្តោតលើបំណិនគិតកម្រិតខ្ពស់។ អ្នកដឹកនាំសាលារៀនអាចផ្លាស់ប្តូរវប្បធម៌របស់សាលារៀនឱ្យចាកឆ្ងាយពីការរៀនដើម្បីតែប្រឡង និងការប្រើតែសៀវភៅសិក្សាគោល ដោយផ្តោតអារម្មណ៍យ៉ាងខ្លាំងលើការជំរុញការស្រាវជ្រាវរបស់សិស្សភ្ជាប់ទៅនឹងការប្រើប្រាស់បណ្ណាល័យសតវត្សទី ២១ នៅក្នុងសាលារៀននីមួយៗ។

បើទោះបីជាសាលារៀនសាធារណៈធម្មតាមិនអាចធ្វើការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីគរុកោសល្យដូចសាលាជំនាន់ថ្មីក៏ដោយ ក៏មានមេរៀនគួរឱ្យទាក់ទាញមួយចំនួនដែលអាចរៀនសូត្រពីសាលារៀនជំនាន់ថ្មី។ ឧទាហរណ៍ ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈគ្រូដោយរៀបចំឱ្យគ្រូបង្រៀនទំនាក់ទំនងគ្នាតាមបណ្តាញសង្គមដែលមិនតម្រូវឱ្យមានការវិនិយោគច្រើននោះទេ។ ដូចគ្នានេះដែរ សាលារៀនអាចជំរុញឱ្យគ្រូបង្រៀនធ្វើការងារគម្រោង និងការស្រាវជ្រាវក្នុងបណ្ណាល័យ នឹងជួយសាលារៀនងាកចេញបានខ្លះពីការសិក្សាដើម្បីតែការប្រឡង។ ភាពជាអ្នកដឹកនាំសាលាខ្លាំង គឺចាំបាច់ណាស់សម្រាប់ការផ្លាស់ប្តូរបែបនេះ។

អ្វីៗសាលារៀនអាចសម្រេចចិត្តធ្វើបាន ប៉ុន្តែចំណុចសំខាន់ដែលត្រូវចងចាំនោះគឺ ការផ្លាស់ប្តូរលើការអនុវត្តរបស់គ្រូមិនអាចកើតឡើងដោយគ្មានឥទ្ធិពលជះពីកត្តាផ្សេងៗឡើយ ដូច្នោះការបង្កើតប្រព័ន្ធអេកូឡូស៊ីអាចជួយពង្រីកការផ្លាស់ប្តូរទាំងនោះបាន។ ជាពិសេស អ្នករៀបចំផែនការសាលារៀនត្រូវតែចងចាំថា ការផ្តល់សិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្រៀនតែមួយមុខ ទំនងជាបង្កើតផលប៉ះពាល់តិចតួចដល់ការអនុវត្តការបង្រៀន។ ការបន្ថែមលក្ខណៈពិសេសទៅក្នុងប្រព័ន្ធអេកូឡូស៊ីរបស់សាលា ដូចជាការចែករំលែកប្រកបដោយវិជ្ជាជីវៈ និងការគាំទ្រផ្នែកប្រឹក្សាគរុកោសល្យ ទំនងជាមានឥទ្ធិពលយ៉ាងខ្លាំងដល់គ្រូបង្រៀនលើការទទួលយកវិធីសាស្ត្របង្រៀនថ្មីៗ ដូចដែលការស្រាវជ្រាវបានអះអាង (សូមមើលប្រអប់ទី ៧)។

## សំណួរពិភាក្សា

១. នៅពេលគិតអំពីសាលាផ្ទាល់ខ្លួន ឬសាលាដែលអ្នកបានសិក្សា តើអ្នកគិតថាត្រូវការកែលម្អអ្វីខ្លះដែលអាចគាំទ្រដល់ប្រសិទ្ធភាពក្នុងការផ្លាស់ប្តូរការអនុវត្តការបង្រៀន? ចូរពន្យល់ពីរបៀបដែលការកែលម្អទាំងនេះអាចផ្តល់ផលប៉ះពាល់ដល់ការបង្រៀន និងការរៀននៅក្នុងថ្នាក់រៀន។

២. តើអ្នកគិតថាការប្រៀបធៀបរវាងប្រព័ន្ធអេកូឡូស៊ី 'ធម្មជាតិ' និងប្រព័ន្ធអេកូឡូស៊ី 'គរុកោសល្យ' ដែលបានពិពណ៌នាខាងលើ ជាពាក្យប្រៀបធៀបត្រឹមត្រូវឬទេ? ហេតុអ្វីត្រឹមត្រូវ ឬហេតុអ្វីមិនត្រឹមត្រូវ?

៣. សាលារៀនជំនាន់ថ្មីអាចធ្វើការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងប្រព័ន្ធអេកូឡូស៊ីគរុកោសល្យរបស់ពួកគេដោយសារការវិនិយោគសំយោគដើម្បីគាំទ្រទិដ្ឋភាពជាច្រើននៃបរិយាកាសសាលា (ឧទាហរណ៍ ភាពជាអ្នកដឹកនាំ ការប្រឹក្សាគរុកោសល្យ ការកែលម្អបណ្ណាល័យ។ល។)។ តើអ្នកគិតថាបទពិសោធន៍ពីសាលារៀនជំនាន់ថ្មី ទាក់ទងនឹងការកែលម្អប្រព័ន្ធអេកូឡូស៊ីគរុកោសល្យ មានការពាក់ព័ន្ធនឹងសាលារៀនធម្មតាយដែរឬទេ? ចូរពន្យល់ចម្លើយរបស់អ្នក។

៤. ទោះបីជាសាលារៀនធម្មតាមិនមានការវិនិយោគទាំងអស់ដូចសាលារៀនជំនាន់ថ្មីក៏ដោយ តើអ្នកគិតថានៅមានអ្វីដែលអាចធ្វើបានដើម្បីកែលម្អប្រព័ន្ធអេកូឡូស៊ីគរុកោសល្យទាំងមូលនៅសាលារៀននោះឬទេ?

៥. តាមគំនិតរបស់អ្នក តើធាតុអ្វីខ្លះនៃប្រព័ន្ធអេកូឡូស៊ីគរុកោសល្យដែលបានពិពណ៌នាខាងលើមានសារៈសំខាន់បំផុតទាក់ទងនឹងការផ្លាស់ប្តូរនៅក្នុងសាលារៀន? ចូរពន្យល់ចម្លើយរបស់អ្នក។

## អំណានបន្ថែម




1. World Education (2019) *What is a Learning Ecosystem,* In EdTech Center@Worldeducation.
   https://edtech.worlded.org/what-is-a-learning-ecosystem/

2. Elias, M.J. (2016) *What Kind of Ecosystem Is Your School?* In Edutopia
   https://www.edutopia.org/blog/what-kind-ecosystem-your-school-maurice-elias

# ៥. វិធីសាស្ត្របង្រៀនបែបសំយោគ ( Hybridized Method ) សម្រាប់ការសិក្សាបែបបញ្ញត្តិ

## ៥.១ គុណសម្បត្តិនៃការបង្កើតវិធីសាស្ត្របង្រៀនបែបសំយោគ

បញ្ហាសំខាន់មួយដែលបានលើកឡើងពីមុន នៅក្នុងឯកសារក្របខណ្ឌនេះទាក់ទងនឹងទំនោររបស់អ្នកអប់រំមួយចំនួន ដែលចង់ជំរុញវិធីសាស្ត្របង្រៀនតាមបែបរូបមន្ត។ ទំនោរនេះ ជារឿយៗ ស្តែងឱ្យឃើញតាមរយៈការអនុម័តយ៉ាងតឹងរឹងនូវវិធីសាស្ត្រមួយ ឬវិធីសាស្ត្រផ្សេងទៀត ដោយមិនគិតពីបរិបទជាក់លាក់ ឬវត្ថុបំណងអប់រំដែលត្រូវបង្រៀន។ វិធីសាស្ត្របង្រៀនបែបរូបមន្ត ច្រើនតែនាំឱ្យការបង្រៀនមិនបានត្រឹមត្រូវ និងគ្មានប្រសិទ្ធភាព។ ដូច្នេះហើយ អ្នកកែទម្រង់វិស័យអប់រំនៅកម្ពុជា បានស្វែងរកការលើកកម្ពស់ការប្រើប្រាស់យុទ្ធសាស្ត្របង្រៀនបែបសំយោគដល់គ្រូបង្រៀន។ វិធីសាស្ត្រនេះតម្រូវឱ្យគ្រូបង្រៀនពិចារណាអំពីបរិបទ និងវត្ថុបំណងអប់រំដែលអាចវាស់វែងបាន។ ប្រសិនបើគ្រូបង្រៀនទទួលយកវិធីសាស្ត្របង្រៀននេះ ដោយចេះពិចារណាពីបរិបទនិងវត្ថុបំណងអប់រំជាមុន នឹងនាំឱ្យពួកគេមានការយល់ដឹងកាន់តែខ្លាំងអំពី 'មូលហេតុ' ដែលពួកគេកំពុងប្រើវិធីសាស្ត្របង្រៀនណាមួយ ជាជាងការប្រកាន់ខ្ជាប់ដោយមេកានិចទៅនឹងការបង្គាប់បញ្ជាដ៏តឹងរ៉ឹងឱ្យប្រើប្រាស់វិធីសាស្ត្រពិសេសណាមួយ។

នៅពេលដែលគ្រូបង្រៀនពិចារណាពីវត្ថុបំណងអប់រំ និងបរិបទរបស់ពួកគេដោយយកចិត្តទុកដាក់ វាទំនងជាថាពួកគេនឹងចេះសំយោគប្រកបដោយយុទ្ធសាស្ត្រនូវល្បិចបង្រៀនខុសៗគ្នាជាច្រើនពីវិធីសាស្ត្រផ្សេងៗ។ ពួកគេចេះរួមបញ្ចូលគ្នានូវល្បិចទាំងនេះដើម្បីបង្កើតវិធីសាស្ត្របង្រៀនប្លែកថ្មី ដោយមានការយល់ដឹងពី "មូលហេតុ" នឹងរបៀបដែលពួកគេធ្វើបែបនោះបានច្បាស់លាស់។

**តារាង ៥.១៖ ឧទាហរណ៍អំពីរបៀបដែលគ្រូអាចសំយោគវិធីសាស្ត្រដើម្បីសម្របទៅតាមបរិបទជាក់លាក់មួយ**

| ឧទាហរណ៍នៃបរិបទអប់រំ | ល្បិចបង្រៀនពាក់ព័ន្ធនឹងវិធីសាស្ត្របង្រៀន | ការអនុវត្តវិធីសាស្ត្របង្រៀនបែបសំយោគ ( យុទ្ធសាស្ត្រ ) |
|---|---|---|
| ថ្នាក់រៀននៅតាមទីជនបទមួយមានសិស្សច្រើនដែលមានសិស្សជិត ៥០ នាក់។ សិស្សទាំងនេះមិនដែលធ្លាប់រៀនសូត្រដែលដឹកនាំដោយខ្លួនឯងពីមុនទេ | **ការសិក្សាបែបសហការ**<br>• រៀបចំសិស្សជាក្រុមសំយោគសមត្ថភាពពី៤ ទៅ៦ក្រុម<br>• បែងចែកតួនាទីចូលរួមធ្វើការងារ<br>• គ្រូបង្រៀនដើរត្រួតពិនិត្យការងារក្រុម<br>• ក្រុមសិស្សធ្វើរបាយការណ៍ ឬបទបង្ហាញ | • គ្រូផ្តល់នូវបញ្ហាបញ្ហាដែលអាចកើតមានក្នុងបរិស្ថាន ( ឧទាហរណ៍ ការទុកដាក់សំរាម ការកែច្នៃ ការបំពុលខ្យល់ ការបំផុលទឹក ) សម្រាប់សិស្សជ្រើសរើសនិងពិចារណាថាតើនេះជាបញ្ហាពិត |

| | | |
|---|---|---|
| ហើយជំនាញស្រាវជ្រាវក៏មានកម្រិត។ គោលបំណងនៃការសិក្សាមានដូចខាងក្រោម៖<br>• សិស្សអាចកំណត់បញ្ហាដែលទាក់ទងនឹងបរិស្ថាននៅក្នុងសហគមន៍របស់ពួកគេ។<br>• សិស្សអាចស្នើដំណោះស្រាយចំពោះបញ្ហាដែលពួកគេបានរកឃើញតាមរយៈការស្រាវជ្រាវនិងការពិភាក្សា។ | **ការសិក្សាបែបរិះរក**<br>• សិស្សកំណត់សំណួរដែលពួកគេចង់រកចម្លើយ<br>• សិស្សស្រាវជ្រាវ<br>• សិស្សធ្វើបទបង្ហាញ<br>• សិស្សឆ្លុះបញ្ចាំងលើដំណើរការដែលមានដំណើរការល្អ /មិនល្អ<br>**ការសិក្សាអាស្រ័យលើបញ្ហា**<br>• ជំហានទី ១៖ ស្វែងយល់ និងកំណត់បញ្ហា<br>• ជំហានទី ២៖ សិស្សនិយាយពីអ្វីដែលពួកគេបានដឹង...<br>• ជំហានទី ៣៖ សិស្សកំណត់និយមន័យបញ្ហា ...<br>• ជំហានទី ៤៖ សិស្សស្រាវជ្រាវចំណេះដឹង ...<br>• ជំហានទី ៥៖ ស៊ើបអង្កេតរកដំណោះស្រាយ ...<br>• ជំហានទី ៦៖ បង្ហាញ និងគាំទ្រដំណោះស្រាយដែលបានរកឃើញ ...<br>• ជំហានទី ៧៖ សិស្សត្រួតពិនិត្យលទ្ធផលការងារពួកគេឡើងវិញ។ | នៅក្នុងបរិស្ថានរបស់ពួកគេដែរឬទេ។ បច្ចេកទេសនេះនៅតែផ្តល់ឱ្យសិស្សគ្រប់គ្រងលើបញ្ហាកំណត់បញ្ហា ប៉ុន្តែត្រូវទទួលស្គាល់ថាសិស្សមិនទាន់ស៊ាំនឹងការរៀនសូត្រដែលដឹកនាំដោយខ្លួនឯងនោះទេ។<br>• គ្រូបង្រៀនរៀបចំក្រុមចំនួន ៥ ក្រុមដែលមួយក្រុមៗមានសិស្សចំនួន ១០ នាក់ ប៉ុន្តែបង្កើនការពិនិត្យតាមដានជួយដើម្បីធានាថាសិស្សទាំងអស់បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការនេះ។<br>• គ្រូប្រគល់កិច្ចការជាក់លាក់ឱ្យក្រុមនីមួយៗ (ឧ. បញ្ជាក់អ្វីដែលគេដឹងកំណត់បញ្ហា ប្រមូលឯកសារស្រាវជ្រាវ។ ល។ )<br>• សិស្សម្នាក់ឬច្រើននាក់ជួយសរសេរលទ្ធផលរកឃើញនិងដំណោះស្រាយ។<br>• សិស្សម្នាក់ឬច្រើនឡើងបង្ហាញពីលទ្ធផលរកឃើញ / ដំណោះស្រាយ. |

ឧទាហរណ៍អំពីរបៀបដែលគ្រូបង្រៀនធ្វើសំយោគវិធីសាស្ត្រជាច្រើនដើម្បីបំពេញតាមស្ថានភាពជាក់លាក់មួយមានផ្តល់ជូននៅក្នុងតារាង ៥.១ ។ តាមរយៈឧទាហរណ៍នេះ អ្នកអានអាចកត់សម្គាល់ឃើញថា ពេលខ្លះល្បិចបង្រៀនដែលគ្រូយកមកអនុវត្ត ប្រហែលជាមិនសូវសមស្របទេ (ឧ. រៀបចំសិស្សជាក្រុមដោយមានសិស្សច្រើន) ប៉ុន្តែពួកគេទទួលស្គាល់ហើយត្រូវធ្វើបែបនោះដោយសារសិស្សក្នុងថ្នាក់មានចំនួនច្រើនពេក។ ក្នុងករណីបែបនេះ គ្រូបង្រៀនត្រូវតែស្វែងរកវិធីផ្សេងទៀតដើម្បីទូទាត់សងដើម្បីឱ្យមានភាពប្រសើរជាង (ឧ. ដោយបង្កើនសកម្មភាពត្រួតពិនិត្យ តាមដានជួយក្រុមសិស្ស)។ ឧទាហរណ៍នេះបង្ហាញថា វាមិនអាចទៅរួចទេ ប្រសិនបើណែនាំគ្រូបង្រៀនឱ្យប្រើវិធីសាស្ត្រតែមួយគ្រប់ពេលវេលា ប៉ុន្តែជម្រើសល្អគឺណែនាំឱ្យគ្រូបង្រៀនបង្កើតវិធីសាស្ត្រសំយោគដោយខ្ចី បញ្ចូលគ្នា និងកែប្រែល្បិចបង្រៀនពីវិធីសាស្ត្រច្រើន។

## ៥.២ អ្វីជាការសិក្សាបែបស្ថាបនានិយម?

ដើម្បីឆ្លើយតបទៅនឹង ការសិក្សាបែបបញ្ញត្តិ ប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជា ត្រូវផ្លាស់ប្តូរពីគំរូ 'ការសិក្សាបែបអកម្ម' ដែលសិស្សគ្រាន់តែជា 'ប្រដាប់សម្រាប់ទទួល' ចំណេះដឹង ទៅកាន់វិធីសាស្ត្រថ្មី ដែលសិស្សរៀនយ៉ាងសកម្មជា 'អ្នកស្ថាបនា' ចំណេះដឹងថ្មី។ គោលវិធីសិក្សា បែបស្ថាបនានិយមគឺជាយានដ៏ល្អមួយ ដើម្បីសម្រេចបាននូវការផ្លាស់ប្តូរបែបនេះ (សូមមើលប្រអប់ទី ៨)។ នៅពេលដែលប្រទេសកម្ពុជាឈានចូលសតវត្សទី ២១ មានតម្រូវការកាន់តែច្រើនឡើងសម្រាប់ប្រព័ន្ធអប់រំ ដើម្បីផលិតកម្លាំងការងារដែលអាចគិតបែបស៊ីជម្រៅ ដោះស្រាយបញ្ហា និងធ្វើការរួមគ្នា។ វិធីសាស្ត្របង្រៀនបែបមេកានិកកាលពីអតីតកាលដែលផ្តោតយ៉ាងខ្លាំងលើការទន្ទេញចាំមាត់គឺមិនអាចឆ្លើយតបតម្រូវការទាំងនេះបានទេ។ ការសិក្សាបែបស្ថាបនានិយមបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមបែបនេះ។

**ប្រអប់ទី ៨៖ និយមន័យការសិក្សាបែបស្ថាបនានិយម**

ការសិក្សាបែបស្ថាបនានិយម គឺជា 'គោលវិធីសិក្សាដែលធ្វើឱ្យមនុស្សបង្កើតចំណេះដឹងដោយខ្លួនឯងយ៉ាងសកម្ម ហើយចំណេះដឹងពិតត្រូវបានកំណត់ដោយបទពិសោធន៍របស់អ្នកសិក្សា។ ចំណេះដឹងពិត កើតឡើងពីចំណេះដឹងមានស្រាប់របស់សិស្ស ឬតាមរយៈការស្រាវជ្រាវដែលជាផ្នែកមួយនៃកិច្ចការក្នុងថ្នាក់រៀន។

## ៥.៣ របៀបដែលការសិក្សាបែបស្ថាបនានិយមអាចជួយលើកកម្ពស់ការសិក្សាបែបបញ្ញត្តិ

ការសិក្សាបែបបញ្ញត្តិ ផ្តល់នូវក្របខណ្ឌទ្រឹស្តីថ្មីមួយសម្រាប់អ្នកអប់រំកម្ពុជា ដើម្បីជំរុញការអប់រំឱ្យកាន់តែពាក់ព័ន្ធទៅនឹងតម្រូវការប្រចាំថ្ងៃរបស់សិស្ស ជាពិសេសឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ចសតវត្សទី ២១ ។ CBL មិនមែនជាវិធីសាស្ត្របង្រៀនទេ ប៉ុន្តែជាយុទ្ធសាស្ត្រអប់រំដ៏ទូលំទូលាយ ដែលអាចអនុវត្តបានច្រើនចំពោះការបង្កើតកម្មវិធីសិក្សា ក៏ដូចជាការបង្រៀនផងដែរ។ សិក្ខាបទសំខាន់ៗមួយចំនួននៃ CBL មានសង្ខេបជូននៅក្នុងប្រអប់ទី ៩ ។ លក្ខណៈសំខាន់មួយនៃ CBL មានគោលបំណងជួយសិស្សឱ្យចេះរៀបចំ បង្កើតបញ្ញត្តិយ៉ាងសកម្ម ដែលនាំឱ្យពួកគេទទួលបាន

**ប្រអប់ទី ៩៖ លក្ខណៈសំខាន់ៗនៃការសិក្សាបែបបញ្ញត្តិ (CBL)**

1. CBL គឺជាទស្សនវិជ្ជានៃការរៀនសូត្រដែលមិនត្រឹមតែមានអត្ថន័យសម្រាប់ 'ការបង្រៀន' ប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ 'ការបង្កើតកម្មវិធីសិក្សា' ផងដែរ។
2. នៅក្នុង CBL ការរៀនសូត្រកើតឡើងនៅកម្រិត 'បញ្ញត្តិ' ជាជាង "អង្គហេតុ" ។
3. CBL លើកទឹកចិត្តការសិក្សាតាមគោលវិធីពហុមុខវិជ្ជា ដែលក្នុងនោះមេរៀនមួយអាចឆ្លងកាត់មុខវិជ្ជាជាច្រើន។
4. CBL ផ្តោតលើការអនុវត្តអង្គហេតុ និងបញ្ញត្តិនៅក្នុងពិភព 'ពិត' ជាជាងការទន្ទេញចាំអង្គហេតុ ដូចដែលកើតឡើងក្នុងរបៀបសិក្សាបែបប្រពៃណី។
5. CBL តម្រូវឱ្យសិស្សមើលឃើញពីការរួមផ្សំគ្នារវាងអង្គហេតុ និងបញ្ញត្តិ។ CBL បង្កើតអន្តរកម្មរវាងគំនិត ដើម្បីឱ្យសិស្សអាចមើលឃើញពីរបៀបដែលគំនិតអាចប្រែប្រួល ឬវិវឌ្ឍតាមពេលវេលា និងតាមបរិបទផ្សេងៗ។

នូវអំណាចក្នុងការគិតបែបស៊ីជម្រៅ។ នេះអាចបង្ហាញពីសមត្ថភាពរបស់សិស្សចេះដកស្រង់ឧទាហរណ៍គោលការណ៍ចេញពីអ្វីដែលពួកគេបានរៀន ពន្យល់ពីរបៀបដែលគោលការណ៍អាចត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាដែលគេផ្ដល់ឱ្យ ឬបញ្ហាដែលបានកំណត់ដោយខ្លួនឯង ឬអាចឈានទៅបង្កើតទ្រឹស្ដី និងសម្មតិកម្មផ្ទាល់ខ្លួនអំពីមូលហេតុនៃអ្វីមួយកើតឡើង។ ការធ្វើគម្រោង បែបបុគ្គល ឬក្រុម គឺជាយានដ៏ល្អមួយដើម្បីជួយសិស្សសម្រេចបាននូវគោលបំណងបែបនេះ។




ដោយមើលឃើញពីតម្រូវការរបស់ CBL ដូចដែលបានរៀបរាប់ខាងលើ ប្រទេសកម្ពុជាត្រូវអនុវត្តវិធីសាស្ត្របង្រៀន និងរៀនដែលមានលក្ខណៈសំយោគ ហើយអាចសម្រុះសម្រួលដល់វិធីសាស្ត្រជាច្រើន ដើម្បីឈានទៅលើកកម្ពស់ការរិះរក និងការបង្កើតបញ្ញត្តិ។ សរុបមក នេះមានន័យថា ការបង្កើតចំណេះដឹងមិនមែនជាអ្វីមួយដែលនឹងថ្កល់ (ឧ. អង្គហេតុ) ប៉ុន្តែវាជាការផ្លាស់ប្ដូរយ៉ាងសកម្ម អាស្រ័យលើបរិបទ ឬបញ្ហាដែលវាត្រូវបានអនុវត្ត។ ដូចការរៀបរាប់ខាងលើ ការសិក្សាបែបស្ថាបនានិយម គឺជាគោលវិធីអប់រំដែលស័ក្តិសមជាខ្លាំងក្នុងការបំពេញតម្រូវការទាំងនេះ ព្រោះវាត្រូវបានបង្កើតឡើងដោយមានលក្ខណៈចម្រុះ និងលើកកម្ពស់យ៉ាងសកម្មនូវចំណេះដឹង ដោយសិស្សជាអ្នកបង្កើតចំណេះដឹងយ៉ាងសកម្មដោយខ្លួនឯង។ ការសិក្សាបែបស្ថាបនានិយម គឺជាទ្រឹស្ដីទូលំទូលាយសម្រាប់ការបង្រៀន និងការរៀនដែលទទួលយកនូវបញ្ញត្តិគុណកោសល្យជាច្រើនដែលពាក់ព័ន្ធនឹង CBL ។ លក្ខណៈសំខាន់នៃគោលវិធីនេះគឺនិយាយអំពីសមត្ថភាពរបស់សិស្សក្នុងការបង្កើតបញ្ញត្តិដែលក្នុងនោះមានធាតុពាក់ព័ន្ធជាច្រើន ដែលរួមមានការគិតបែបស៊ីជម្រៅ ការដោះស្រាយបញ្ហា ការសិក្សាបែបសហការ និងការប្រើប្រាស់បច្ចេកវិទ្យា ។ល។ ការរៀនតាមបែប ស្ថាបនានិយមក៏បានស្រូបទាញវិធីសាស្ត្របង្រៀនផ្សេងទៀតជាច្រើនដែលមានគោលដៅស្រដៀងគ្នាដូចជា ការសិក្សាអាស្រ័យលើបញ្ហា ការសិក្សាបែបស្រាវជ្រាវ វិធីសាស្ត្រសិក្សាបែបរិះរក និងការរៀនបែបសហការ។ ដូច្នេះ ការសិក្សាបែបស្ថាបនានិយម គឺជាទ្រឹស្ដីនៃការរៀនដែលមានលក្ខណៈចម្រុះបំផុត ដែលស្រូបយកវិធីសាស្ត្របង្រៀនផ្សេងៗទៀត។ ការសិក្សាបែបស្ថាបនានិយមជួយបង្កើតអព្យាក្រឹតភាពមិនឱ្យមានការប្រកួតប្រជែងរវាងវិធីសាស្ត្រផ្សេងគ្នាទាំងអស់ដោយសារតែវាមានលក្ខណៈចម្រុះ និងសមត្ថភាពក្នុងការសម្រុះសម្រួលវិធីសាស្ត្រជាច្រើនឱ្យនៅក្រោមដំបូលតែមួយ។

## ៥.៤ ការសិក្សាបែបស្ថាបនានិយម និងបច្ចេកវិទ្យា



ការសិក្សាបែបស្ថាបនានិយម មានតាំងពីយូរយារណាស់មក ហើយ ប៉ុន្តែភាពពាក់ព័ន្ធរបស់វាសមស្រប និងបានកើនឡើងយ៉ាងខ្លាំង នៅពេលដែលពិភពលោកឈានចូលដល់យុគសម័យព័ត៌មាន។ បច្ចេកវិទ្យាព័ត៌មានបានពង្រីកសក្តានុពលការសិក្សាតាមបែបស្ថាបនានិយម ដើម្បីលើកកម្ពស់ការរៀនបែបសហការ (ឧ. តាមរយៈបណ្តាញ) ដើម្បីបង្កើត និងសំយោគព័ត៌មានថ្មីៗ (ឧ. តាមរយៈការបង្ហាញដោយកម្មវិធី PowerPoint) និងដោះស្រាយបញ្ហា (ឧ. តាមរយៈកម្មវិធីដំណើរការទិន្នន័យដែលអាចស្វែងរកទំនាក់ទំនង តម្រៀបទិន្នន័យ។ល។)។ ដូច្នេះ ការប្រើប្រាស់បច្ចេកវិទ្យាអាចជាឧបករណ៍ដ៏ល្អមួយ ដើម្បីជួយសិស្សឱ្យរៀបចំបញ្ញត្តិ ដែលជាលក្ខណៈស្នូលរបស់ការសិក្សាបែបបញ្ញត្តិ និងការសិក្សាបែបស្ថាបនានិយម។ ការសិក្សាបែបស្ថាបនានិយម លើកកម្ពស់យ៉ាងខ្ពស់នូវការគិតបែបស៊ីជម្រៅ ជួយទៅលើការរៀបចំ ឬបង្កើតបញ្ញត្តិ ដែលជាបំណិនដ៏សំខាន់បំផុតមួយសម្រាប់កម្លាំងពលកម្មក្នុងយុគសម័យព័ត៌មាន។ ដូច្នេះ **ការសិក្សាបែបស្ថាបនានិយម បច្ចេកវិទ្យា** និង**តម្រូវការនៃកម្លាំងពលកម្មនៅសតវត្សរ៍ទី២១** គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នា។

## សំណួរពិភាក្សា

១. តើអ្នកគិតថាអ្វីជាគុណសម្បត្តិ និងគុណវិបត្តិនៃវិធីសាស្ត្របែបសំយោគដើម្បីលើកកម្ពស់ការសិក្សាតាមបែបបញ្ញត្តិ? ចូរពន្យល់ថាតើអ្នកគិតថាវាមានគុណសម្បត្តិលើសពីគុណវិបត្តិ ឬផ្ទុយមកវិញ។

២. ការសិក្សាបែបបញ្ញត្តិ នៅទីនេះគេហៅថាជា 'យុទ្ធសាស្ត្រ' ក្នុងការបង្រៀន និងការរៀន ជាជាងហៅវាថាជា គោលវិធី ឬទស្សនវិជ្ជា។ តើអ្នកយល់ស្របនឹងការកំណត់នេះឬទេ ឬ អ្នកគិតថា CBL គួរតែហៅថាជា គោលវិធី ដែរ? សូមពន្យល់ចម្លើយរបស់អ្នក។

៣. តើអ្នកយល់ស្របនឹងសំណើដែលថា ការសិក្សាបែបស្ថាបនានិយម គឺជាទ្រឹស្តីទូលំទូលាយគ្រប់គ្រាន់មួយ ដែលអាចសម្រុះសម្រួលវិធីសាស្ត្រផ្សេងៗទៀតដូចជា ការសិក្សាបែបរិះរក ការសិក្សាអាស្រ័យលើបញ្ហា និង ការសិក្សាបែបសហការ ឱ្យនៅក្រោមដំបូលតែមួយ ហើយជាលទ្ធផលនាំទៅដល់ការបង្រៀនបែបសំយោគឬទេ? ហេតុអ្វី ឬហេតុអ្វីមិន?

៤. តើអ្នកអាចគិតពីឧទាហរណ៍បន្ថែមអំពីបរិបទសិក្សា ណាខ្លះទៀតដែលទាមទារឱ្យអនុវត្តតាមវិធីសាស្ត្របង្រៀន និងរៀនបែបសំយោគបានទេ? សូមប្រើរចនាសម្ព័ន្ធដែលមាននៅក្នុងតារាង ៥.១ ដើម្បីបង្ហាញឧទាហរណ៍ផ្ទាល់ខ្លួនរបស់អ្នក។

# អំណានបន្ថែម




1. McLeod, S., (2019) *Constructivism as a Theory for Teaching & Learning,* In Simple Psychology.
   https://www.simplypsychology.org/constructivism.html

2. KAPE (2016) Constructivist Training Manual, Phnom Penh: MoEYS.
   http://www.kapekh.org/files/report_file/166-en.pdf

3. Murphy, A., (2017) *A Quick Guide to Concept-based Learning and Curriculum,* In Atlas Next.
   https://www.onatlas.com/blog/concept-based-learning-curriculum

# ឧបសម្ព័ន្ធទី១៖ ទស្សនវិជ្ជាអប់រំទាំងប្រាំពីរ

| ទស្សនវិជ្ជាអប់រំ | មូលហេតុដែលត្រូវបង្រៀន | អ្វីដែលត្រូវបង្រៀន | របៀបបង្រៀន |
|---|---|---|---|
| 1. **ការសិក្សាបែបស្ថាបនានិយម** (Constructivism) | • ដើម្បីអភិវឌ្ឍសិស្សឱ្យចេះលើកទឹកចិត្តខ្លួនឯងពីខាងក្នុង និងឯករាជ្យ បណ្តុះបំណិនសិក្សាគ្រប់គ្រាន់ដល់ពួកគេ ដើម្បីបង្កើតចំណេះដឹង និងបង្កើតអត្តន័យ។ | • សិស្សត្រូវបានបង្រៀនពីរបៀបរៀន (ឱ្យចេះរៀនដោយខ្លួនឯង)។<br>• ពួកគេត្រូវបានបង្រៀនពីដំណើរ និងបំណិនសិក្សាដូចជាការស្រាវជ្រាវ ការវិភាគ និងការវាយតម្លៃលើព័ត៌មាន។ | • គ្រូបង្រៀនផ្តល់ឱ្យសិស្សនូវទិន្នន័យ ឬបទពិសោធន៍ដែលបង្កឱ្យពួកគេចេះបង្កើតសម្មតិកម្ម ទស្សន៍ទាយ រៀបចំបង្កើតវត្ថុ បង្កើតសំណួរ ស្រាវជ្រាវ ស៊ើបអង្កេត ស្រមៃ និងបង្កើត។ |
| 2. **ការសិក្សាបែបមូលដ្ឋាននិយម** (Essentialism) | • ទស្សនវិជ្ជានេះមានគោលបំណងណែនាំគ្រូបង្រៀន ឱ្យបង្រៀនសិស្សទទួលបានចំណេះដឹងបំណិន និងគុណតម្លៃ ជាមូលដ្ឋាន។ | • សង្កត់ធ្ងន់ទៅនៅលើខ្លឹមសារសិក្សាសម្រាប់សិស្សានុសិស្ស ដើម្បីរៀនបំណិនមូលដ្ឋាន និងគ្រឹះសម្រាប់ អំណាន សំណេរ គណិតវិទ្យា និង អាកប្បកិរិយាត្រឹមត្រូវ។<br>• គ្រូបង្រៀន និងអ្នករដ្ឋបាលជាអ្នកសម្រេចចិត្តថាអ្វីដែលសំខាន់បំផុតសម្រាប់សិស្សរៀន។ | • គ្រូបង្រៀនមូលដ្ឋាននិយមសង្កត់ធ្ងន់លើការបណ្តុះភាពស្ទាត់ចំណេះជំនាញលើមុខវិជ្ជា។<br>• គ្រូបង្រៀនត្រូវធ្វើជាគំរូទាំងខាងបញ្ញា និងសីលធម៌ដល់សិស្សរបស់ពួកគេ។<br>• គ្រូបង្រៀនគឺជា "ប្រភពចំណេះដឹង" និងជា "គំរូនៃគុណធម៌"។ |
| 3. **ការសិក្សាបែបវឌ្ឍនភាពនិយម** (Progressivism) | • គ្រូបង្រៀនវឌ្ឍនភាពនិយម បង្រៀនសិស្សឱ្យក្លាយជា | • អ្នកវឌ្ឍនភាពនិយមត្រូវបានកំណត់ដោយការ | • គ្រូបង្រៀនវឌ្ឍនភាពនិយមប្រើវិធីសាស្ត្រ |

| ទស្សនវិជ្ជាអប់រំ | មូលហេតុដែលត្រូវបង្រៀន | អ្វីដែលត្រូវបង្រៀន | របៀបបង្រៀន |
|---|---|---|---|
| | ពលរដ្ឋដែលចេះដឹង និងឆ្លាតវៃសម្រាប់សង្គមប្រជាធិបតេយ្យ។ | បង្កើតកម្មវិធីសិក្សាផ្អែកលើតម្រូវការ និងការឆ្លើយតប។<br>• កម្មវិធីសិក្សាគួរតែឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស ហើយដែលទាក់ទងនឹងជីវិត និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់សិស្ស។ | ផ្អែកលើបទពិសោធន៍។ |
| 4. ការសិក្សាបែបសកលនិយម (Perennialism) | • ដើម្បីអភិវឌ្ឍអំណាចនៃការគិតបែបសមហេតុផល និងសីលធម៌របស់សិស្ស។ | • កម្មវិធីសិក្សាបែបសកលនិយម គឺមានលក្ខណៈសកលត្រូវនឹងធម្មជាតិរបស់មនុស្សជាតិទាំងអស់នៅក្នុងលោក។<br>• វាមិនមែនជាកម្មវិធីសិក្សាបែបឯកទេសនោះទេ ប៉ុន្តែវាមានលក្ខណៈជាកម្មវិធីសិក្សាទូទៅ។ | • ថ្នាក់រៀនបែបសកលនិយមគឺមានលក្ខណៈជា "គ្រូបង្រៀនមជ្ឈមណ្ឌល"។<br>• គ្រូបង្រៀនមិនធ្វើទៅតាមចំណាប់អារម្មណ៍ និងបទពិសោធន៍របស់សិស្ស ពោលគឺសិស្សរៀនតាមអ្វីៗដែលពួកគេបង្រៀន។ |
| 5. ការសិក្សាបែបអត្ថិភាពនិយម (Existentialism) | • ដើម្បីជួយសិស្សឱ្យយល់ និងឱ្យតម្លៃលើខ្លួនឯងថាជាបុគ្គលតែមួយគត់ដែលទទួលយកការទទួលខុសត្រូវទាំងស្រុងចំពោះ | • នៅក្នុងកម្មវិធីសិក្សាបែបអត្ថិភាពនិយម សិស្សត្រូវបានផ្តល់ឱ្យនូវវិធីជាច្រើនសម្រាប់ជ្រើសរើស។ | • ការសិក្សាបែបអត្ថិភាពនិយមផ្តោតទៅលើបុគ្គល។<br>• ទស្សនវិជ្ជានេះជួយសិស្សឱ្យស្គាល់ខ្លួនឯង និងទីកន្លែងដែលពួកគេនៅក្នុងសង្គម។ |

| ទស្សនវិជ្ជាអប់រំ | មូលហេតុដែលត្រូវបង្រៀន | អ្វីដែលត្រូវបង្រៀន | របៀបបង្រៀន |
|---|---|---|---|
| | គំនិត អារម្មណ៍ និងសកម្មភាពរបស់ខ្លួន។<br>• ដើម្បីជួយសិស្សឱ្យចេះកំណត់ខ្លឹមសារផ្ទាល់ខ្លួន ដោយបង្ហាញពួកគេនូវផ្លូវផ្សេងៗដែលពួកគេដើរក្នុងជីវិត។ | • ផ្ដល់ឱ្យសិស្សនូវបទពិសោធន៍ផ្សេងៗ ដែលនឹងជួយបញ្ចេញនូវគំនិតច្នៃប្រឌិត និងការបញ្ចេញមតិដោយខ្លួនឯង។ | |
| 6. **ការសិក្សាបែបអាកប្បកិរិយានិយម** (Behaviorism) | • សាលារៀនអាកប្បកិរិយានិយម មានគោលបំណងកែប្រែ និងកសាងអាកប្បកិរិយារបស់សិស្ស ដោយផ្ដល់នូវបរិយាកាសអំណោយផល។ | • គ្រូបង្រៀនអាកប្បកិរិយានិយម បង្រៀនសិស្សឱ្យឆ្លើយតបវិញដោយពេញចិត្តទៅនឹងគ្រឿងរំញោច (គ្រឿងលើកទឹកចិត្ត) ផ្សេងៗនៅក្នុងបរិស្ថាន។ | • គ្រូបង្រៀនអាកប្បកិរិយានិយមគួររៀបចំលក្ខខណ្ឌបរិស្ថាន ដើម្បីឱ្យសិស្សអាចធ្វើការឆ្លើយតបទៅនឹងគ្រឿងរំញោច (គ្រឿងលើកទឹកចិត្ត)។<br>• គ្រូបង្រៀនគួរតែបង្កើតគ្រឿងរំញោចឱ្យបានច្បាស់លាស់ និងគួរឱ្យចាប់អារម្មណ៍ ដើម្បីចាប់យក និងរក្សាបាននូវបម្រុងប្រយត្នរបស់សិស្ស។<br>• ពួកគេគួរតែផ្ដល់នូវការលើកទឹកចិត្តសមស្រប ដើម្បីពង្រឹងការឆ្លើយតបជាវិជ្ជមាន និងធ្វើឱ្យចុះខ្សោយនូវចំណុចអវិជ្ជមាន។ |

| ទស្សនវិជ្ជាអប់រំ | មូលហេតុដែលត្រូវបង្រៀន | អ្វីដែលត្រូវបង្រៀន | របៀបបង្រៀន |
|---|---|---|---|
| 7. **ការសិក្សាបែបទំនាក់ទំនងនិយម** ( Linguistic Philosophy ) | • ដើម្បីអភិវឌ្ឍបំណិនទំនាក់ទំនងដល់សិស្ស។<br>• ដើម្បីអភិវឌ្ឍសិស្សនូវបំណិនក្នុងការផ្ញើសារច្បាស់លាស់ និងទទួលសារវិញបានត្រឹមត្រូវ។ | • សិស្សគួរតែបង្រៀនឱ្យប្រាស្រ័យទាក់ទងគ្នាបានច្បាស់លាស់ – របៀបផ្ញើសារដែលខ្លី មានន័យច្បាស់លាស់ និងរបៀបទទួល និងយល់ត្រឹមត្រូវចំពោះសារដែលទទួលបាន។<br>• ការប្រាស្រ័យទាក់ទងគ្នាប្រព្រឹត្តទៅតាមវិធី៣យ៉ាង គឺ ពាក្យសម្ដី កាយវិការ និងពាក្យសម្ដីដោយមានកាយវិការបញ្ជាក់ ( paraverbal )។ | • បទពិសោធន៍គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការបង្រៀនភាសា និងការទំនាក់ទំនង។<br>• គ្រូបង្រៀនសម្របសម្រួលការសន្ទនាក្នុងចំណោមសិស្ស និងរវាងសិស្សរបស់គាត់។ |

ប្រភព៖ **Euphemia Abigael Bas**

# ឧបសម្ព័ន្ធ ២៖
# អន្តរកាលក្នុងវិស័យអប់រំ៖ ការផ្លាស់ប្តូរពីសតវត្សទី ២០ ទៅសតវត្សទី ២១




1




2




3




4




5




6


ថ្នាក់រៀនតាមទ្រឹស្តីថេល័រនិយម. . .

7


ប្រៀបធៀបរោងចក្រថេល័រនិយមទៅនឹងថ្នាក់រៀនថេល័រនិយម...
សូមស្វាគមន៍មកកាន់សតវត្សរ៍ទី២០!

8


ទ្រឹស្តីថេល័រនិយមមកដល់ប្រទេសកម្ពុជា...
• តាមរយៈពួកអាណានិគមនិយមបារាំង ទ្រឹស្តីថេល័រនិយមត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធអប់រំកម្ពុជា
• ឥឡូវនេះយើងមានរោងចក្រអប់រំនៅកម្ពុជាផងដែរ

9


ទ្រឹស្តីថេល័រនិយមនៅក្នុងប្រទេសកម្ពុជា...
• វីដេអូបង្ហាញការអប់រំនៅសម័យសង្គមរាស្ត្រនិយម.mp4

10


តើអ្វីបានផ្លាស់ប្តូរក្នុងរយៈពេល៦០ឆ្នាំ?

11


ការផ្លាស់ប្តូរដ៏ធំបំផុត...

12

## ការប្រៀបធៀបរហ័សមួយ...

| កត្តា | ១៩៦៩ ២០១៩ |
|---|---|
| ការរៀបចំតុ | ដូចគ្នា |
| គ្រឿងសង្ហារឹមថ្នាក់រៀន | ដូចគ្នា |
| វិធីសាស្ត្របង្រៀន | ដូចគ្នា |
| របនាប់ទំអគារសិក្សា | ដូចគ្នា |
| ឯកសណ្ឋាន | ដូចគ្នា |
| ម៉ូតសក់ស្ត្រី | ផ្លាស់ប្តូរ |

13

## 2. ការអប់រំក្នុងសតវត្សរ៍ទី២១

- តម្រូវការរបស់សង្គមបានផ្លាស់ប្តូរទាំងស្រុងបើប្រៀបធៀបទៅនឹងសតវត្សទី ២០

14

## តើសង្គមកំពុងផ្លាស់ប្តូរយ៉ាងដូចម្តេច?

- ចំណេះដឹងមិនមានស្ថេរភាពដូចនៅសតវត្សរ៍ទី២០ទេ
  - គំនិតនៃការប្រើតែសៀវភៅសិក្សាគោលគឺហួសសម័យ
- ម៉ាស៊ីនកំពុងជំនួសមនុស្ស
- ការងារកំពុងបាត់បង់
- ការងារថ្មីកំពុងតែកើតឡើង
- ត្រូវការបង្កើតបាត់មនុស្សឱ្យធ្វើអ្វីដែលម៉ាស៊ីនមិនអាចធ្វើបាន

15

## តើអ្វីទៅជាការអប់រំបែបសតវត្សរ៍ទី២១?

- What is 21st century education- - YouTube.mp4

16

## ប្រៀបធៀបការអប់រំសតវត្សទី២០ និងសតវត្សទី២១

| [illegible] | [illegible] | [illegible] |
|---|---|---|
| 1. [illegible] | [illegible] | [illegible] |
| 2. [illegible] | [illegible] | [illegible] |
| 3. [illegible] | [illegible] | [illegible] |
| 4. [illegible] | [illegible] | [illegible] |
| 5. [illegible] | [illegible] | [illegible] |
| 6. [illegible] | [illegible] | [illegible] |
| 7. [illegible] | [illegible] | [illegible] |

17

## ការសើចចំអកចំពោះការអប់រំនៅសតវត្សទី២០...

- Taylorism in the classroom - YouTube.mp4

ការពិភាក្សា

- *ការសន្និដ្ឋានសំខាន់មួយពីវីដេអូនេះគឺ:*

***គ្រូបង្រៀនមិនចាំបាច់គិតទេ***

- *ហេតុអ្វីនេះជាបញ្ហាសម្រាប់ការអប់រំសតវត្សទី ២១?*

18


3. របៀបដែល NGS ប្រឹងប្រែងដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកនៃសតវត្សទី២១
• ចូរយើងត្រឡប់ទៅតារាងរបៀបរៀបរបស់យើងវិញរវាងការរស់ពីសតវត្សទី ២០ និង ២១ ។
• ក្នុងក្រុមតូចសូមពិភាក្សា មក ឧទាហរណ៍ជាក់លាក់នៃអ្វីដែលយើងគួរធ្វើនៅ NGS ដើម្បីលើកស្ទួយការរស់សតវត្សទី 21...

19


What To Expect In The 21st Century Classroom

20


សូមផ្តល់ឧទាហរណ៍ជាក់ស្តែង...

21


សេចក្តីណែនាំៈ
• សូមបំពេញតារាងជាក្រុមតូចៗនិងបង្ហាញដល់ក្រុមធំ
• ផ្តល់ឧទាហរណ៍ជាក់លាក់អំពីអ្វីដែលអ្នកកំពុងធ្វើឬនឹងធ្វើនៅក្នុងថ្នាក់រៀនរបស់អ្នក
• ពិភាក្សានិងឆ្លើយតបទៅនឹងគំនិតដែលបានបង្ហាញ

22

# ឧបសម្ព័ន្ធ ៣៖ យុទ្ធសាស្ត្រគរុកោសល្យនៅសាលារៀនជំនាន់ថ្មី




1




2




3




4




5




6


ប្រព័ន្ធអេកូឡូស៊ីគរុកោសល្យ

7


២. វិធីសាស្ត្របង្រៀនបែបសំយោគ (Hybridized Learning Method)
Teaching Methodology
(IBL)
(PBL)
(CL)
(Blended Learning)

8


NGS

9


ការសំយោគខ្លឹមសារវិធីសាស្ត្រ...
ការសិក្សាបែបស្ថាបនានិយម

10


និយមន័យ ការសិក្សាបែបស្ថាបនានិយម...

11



12




13



14



15




16



17



18




19




20




21




22




23




24


គំរូ ៧០-២០-១០ . . .

25


អ្វីដែលគួរឲ្យចាប់អារម្មណ៍អំពីការស្រាវជ្រាវនេះគឺថាមានតែ ១០% នៃការផ្លាស់ប្តូរការអនុវត្តរបស់គ្រូបង្រៀនកើតចេញពីសិក្ខាសាលា។
ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់សិក្ខាសាលា ក្លាយជាយុទ្ធសាស្ត្រនាំមុខក្នុងគម្រោងអភិវឌ្ឍន៍ភាគច្រើនទៅវិញ. . .

26


កម្មវិធីបណ្តុះបណ្តាលគ្រូប្រឹក្សាគរុកោសល្យនៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ត្រូវបានបង្កើតយ៉ាងល្អ ហើយអាចមានប្រយោជន៍សម្រាប់វិទ្យាស្ថានបណ្តុះបណ្តាលគ្រូ. . .

27


ការស្វែងរកវិធីសម្រាប់គ្រូប្រឹក្សាគរុកោសល្យគាំទ្រនៅវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ
NGPRC នឹងបណ្តុះបណ្តាលបុគ្គលិកក្រសួងអប់រំឲ្យធ្វើជាគ្រូប្រឹក្សាគរុកោសល្យដែលមានសមត្ថភាពខ្ពស់ ដែលអាចគាំទ្រដល់វិទ្យាស្ថានបណ្តុះបណ្តាលគ្រូ។

28


THANK YOU!

29

# ឧបសម្ព័ន្ធទី ៤៖
# ការយល់ដឹងអំពីកំណែទម្រង់ដំណើរការបង្រៀន និងរៀននៅកម្ពុជា



1




2



3



4



5



6


២. ការយល់ដឹងពីការអប់រំនៅសតវត្សរ៍ទី ២១
21ST CENTURY

7


21ST CENTURY

8


កន្លែងធ្វើការបែបចាស់ និងបន្ទប់រៀនបែបចាស់ - ដែលមានសភាពដូចគ្នា

9


តើសង្គមប្រែប្រួលយ៉ាងដូចម្តេច?
ចំណេះដឹងលែងមានស្ថិរភាពដូចនៅសតវត្សរ៍ទី ២០ទៀតឡើយ
ម៉ាស៊ីនកំពុងធ្វើការជំនួសមនុស្ស
ការងារកំពុងបាត់បង់
ការងារថ្មីកំពុងកើតឡើង
យើងត្រូវការបណ្តុះបណ្តាលមនុស្សឱ្យធ្វើអ្វីដែលម៉ាស៊ីនមិនអាចធ្វើបាន

10


ការផ្លាស់ប្តូរពីការសិក្សាបែបសតវត្សទី ២០ ទៅសតវត្សទី ២១

11



12




13



14



15



16



17




18



19




20



21




22




23